# អាម៉ៅស្តែខ្មែរ

ស៊ូ ចំរើន

ឯកសារពិត

ប្រវត្តិសាស្ត្រខ្មែរ_ចិន



ផ្សាយចេញពីបណ្ណាគារបន្ទាយស្រី

www.elibraryofcambodia.org

ទទួលអំណោយពីលោក ឡៅ ឃុនសំរ៉ែង និងក្រុមការខ្មែរ
ដើម្បីដាក់បញ្ចូលក្នុង elibrary of Cambodia.
កញ្ញា. 2015.

# អាម៉ោកខ្មែរ

រៀបរៀងដោយ

**ស៊ូ ចំរើន**

**បោះពុម្ពដោយ**

**បណ្ណាគារ បន្ទាយស្រី**

**ការីកុំព្យូទ័រ : អ្នកស្រី ម៉ៅ ចណ្ណនឿន**

កែអក្ខរាវិរុទ្ធ ដោយ :

លោកសាស្ត្រាចារ្យអក្សរសាស្ត្រខ្មែរ **ឈុន លិះ**

**រក្សាសិទ្ធិ**

www.elibraryofcambodia.org

# ឯកសារពិគ្រោះ

- ព្រះរាជពង្សាវតាក្រុងកម្ពុជាធិបតីបច្ឆិមសម័យខ្មែរ ៤ ច្បាប់សរសេរដៃតម្កល់ទុកនៅសមាគមអ្នកនិពន្ធខ្មែរ ។

- ឯកសារមហាបុរសខ្មែរស្រាវជ្រាវដោយលោកអេង-សុត បោះពុម្ពក្នុងឆ្នាំ ១៩៦៩ ។

- សៀវភៅប្រជុំពាក្យកាព្យ ប្រមូលចងក្រង ដោយសម្ដេចមាលិកា ផ្សាយចេញពីពុទ្ធសាសនបណ្ឌិត្យ បោះពុម្ពលើកទី១ ឆ្នាំ ១៩៦៨ ។

- ពង្សាវតានៃប្រទេសកម្ពុជា របស់ក្រសួងសិក្សាធិការជាតិ បោះពុម្ពលើកទី១ ឆ្នាំ ១៩៥២ ។

- ទស្សនាវដ្ដីអក្សរសាស្ត្ររបស់សមាគមអ្នកនិពន្ធខ្មែរ លេខ ១៤ ១៥ ១៦ ១៧ ឆ្នាំ ១៩៦៤ អត្ថបទស្រាវជ្រាវដោយលោកឈាង ហ៊បអាន តាមឯកសារជាតិនិងបរទេស :

- Histoire du Cambodge, Adhémard-Leclére, 1914
- Histoire du çambodge, Le Giteau, 1957
- Le Cambodge. Louis Cheminais, 1960
- Histoire du Cambodge, A.Dauphin Meunier, 1961

www.elibraryofcambodia.org

# វគ្គទី១
## សម្តេចព្រះសុគន្ធាមហាសង្ឃរាជា
## គណាធិបតី ជិម

នៅដើមសតវត្សទី១៧ នៃគ្រិស្តសករាជ មានព្រះមហាថេរមួយព្រះអង្គទ្រង់ព្រះនាម សម្តេចព្រះសុគន្ធាមហាសង្ឃរាជាគណាធិបតីជិម ស្តីទីសង្ឃនាយកលើព្រះសង្ឃទាំងពួង ។ ព្រះអង្គប្រកបដោយញាណញៀយ្យនៃទិព្វញាណ ទ្រទ្រង់នូវបិដកធម៌ក្នុងឈានលោកិយវិស័យវិសេសពន់ពេកណាស់ ។ ទ្រង់ស្ទាត់ជំនាញជាញជ័យ អាចដោះស្រាយប្រស្នាអាថិបាលីវាក់ជ្រៅគ្រប់បែបយ៉ាង ពុំទើសទាល់វាក់សេចក្តីដល់ម្តងណាឡើយ ។ ដោយពិតទៅព្រះសុគន្ធាមហាថេរជាឯកអគ្គបណ្ឌិត មានព្រះប្រាជ្ញាឆ្លៀវឆ្លាតឈ្លាសវៃឥតបីផ្ទឹម ។ ព្រះកិត្តិនាមរបស់ព្រះអង្គល្បីរន្ទឺពេញព្រះរាជាណាចក្រពេញទាំងនគរ រហូតដល់ទៅនានាប្រទេសថែមទៀតផង ។

www.elibraryofcambodia.org

ព្រះសុគន្ធាមហាសង្ឃរាជាគណាធិបតី គង់នៅវត្តអ្នកតាសឹងជ័ជាអារាមធ្លើងផ្ថានឋិតក្នុងទីក្រុងឧត្តុង្គមានជ័យ ។ ព្រះអង្គមិនដែលបណ្តែតបណ្តោយឲ្យពេលវេលាកន្លងផុតទៅឥតប្រយោជន៍ទេ ទ្រង់ប្រកាន់យកនូវសេចក្តីព្យាយាមយ៉ាងខ្ជាប់ខ្ជួន ។ ដោយសព្វព្រះទ័យនឹងវប្បធម៌-អក្សរសាស្ត្រ ព្រោះព្រះអង្គយល់ច្បាស់ថា "អក្សររលត់ជាតិរលាយ អក្សរពណ្ណរាយជាតិថ្កុំថ្កើង" សម្តេចបានតាក់តែងស្នាព្រះហស្តនៅគង់វង្សរហូតដល់សព្វថ្ងៃនេះ គឺសាស្ត្រាច្បាប់ក្រមទុកទូន្មានជនានុជនទាំងឡាយ [១] ។

នាព្រឹកមួយ ព្រះទិនវ័ត្ឋបានរះផុតចុងព្រៃព្រឹក្សានានាបាចសាចការស្មីបំភ្លឺទីបលោក ហាក់ប្រៀបបាននឹងឆព្វណ្ណរង្សីដ៏រុងរឿងឫទ្ធិ ដែលផ្សាយចេញពីព្រះកាយព្រះពុទ្ធជិនស្រី ។

ក្សិណនោះ សម្តេចព្រះសុគន្ធាមហាសង្ឃរាជាគណាធិបតីជិម ទ្រង់និមន្តទៅបិណ្ឌបាត្រនៅភ្នំព្រះរាជទ្រព្យ ដែលមានគេហដ្ឋានអ្នកស្រុក ភូមិ ហូរហែចប់តែផ្លូវ ។

កូនសិស្សលោកទុកជុកកំប៉ោយអាយុប្រហែល ៧-៨ ឆ្នាំ

---

១- សូមអានច្បាប់ក្រមក្នុងសៀវភៅច្បាប់ផ្សេងៗរបស់ពុទ្ធសាសនបណ្ឌិត្យ ។

www.elibraryofcambodia.org

បោះជំហានមួយៗ តាមក្រោយព្រះមហាថេរ ។ យូរៗម្តងកុមារនេះស្រែករាងបង្ហួស :

- តា...យាយ...ទាន់ចង្ហាន់លោកទេ...

បងប្អូនខ្មែរយើង មិនថាក្មេងចាស់ប្រុសស្រី សុទ្ធសឹងជាពុទ្ធសាសនិកជន តែងមានសទ្ធាជ្រះថ្លាក្នុងព្រះពុទ្ធសាសនាមុតមាំណាស់ រៀងរាល់រូបយល់ជាក់ថា :

- សូម្បីធ្វើបុណ្យបាយមួយវែកសំណែកមួយកូរ ក៏គង់បានសម្រេចមគ្គផលទៅអនាគតជាតិដែរ ។

បាសកឧបាសិកាចំណោះជើងវត្តអ្នកតាសឹង ទ្រផ្តិលបាយក្តៅហុយៗយកមកដូសដាក់បាត្រ រួចលុតជង្គង់ចុះលើកហត្ថកំបង់អញ្ជលីផុតសិរសាតាំងចិត្តប្រាថ្នា សូមសេចក្តីសុខ-ចម្រើនជានិរន្តរ៍តរៀងទៅ ។

ខ្លះទៀតមានតាំងពីម្ហូបបង្អែម និងផ្លែឈើឲ្យក្មេងសិស្សលោកចាក់ចូលក្នុងចានស្រាក់ ព្រមទាំងកាន់យូរស្នើរផ្ទៀងខ្លួន។

ពេលនោះសម្តេចព្រះសុគន្ធាមហាថេរទ្រង់ទតឃើញសម៉មួយដើម បែកមែកត្រសុំត្រសាយសាខាចោលម្លប់ត្រឈឹងត្រឈៃ

www.elibraryofcambodia.org

គួរឲ្យត្រជាក់ក្នុងហឫទ័យពន់ពេក ព្រះអង្គក៏មានថេរដីកាថា :

- តើធ្វើម្តេចនឹងបានដើមសម៉នេះ ទៅដុះនៅមុខកុដិគ្រាន់មានផ្លែមកចែកព្រះសង្ឃឆាន់...

កាលបើឮជាក់ដូច្នេះហើយ បុរសម្នាក់ឈ្មោះសុកជាម្ចាស់ដើមសម៉នោះ មានចិត្តសទ្ធាជ្រះថ្លាក្រាបថ្វាយបង្គំភ្លាម :

- ទូលព្រះបង្គំជាខ្ញុំ សូមថ្វាយព្រះអង្គតាមសព្វព្រះទ័យ !

- ពរ...អាត្មាសូមប្រសិទ្ធិឲ្យលោកអ្នកសប្បុរសដ៏ចម្រើនប្រកបតែនឹងពុទ្ធពរទាំងប្រាំប្រការគឺអាយុ វណ្ណៈ សុខៈ ពលៈនិងបដិភាណៈ កុំបីឃ្លៀងឃ្លាតឡើយ !

សុកលើកដៃប្រណម្យទទួល :

- សាធុ ៗ ៗ ...

រួចស្រេចហើយ សម្តេចព្រះសុគន្ធាមហាសង្ឃរាជាគណាធិបតីជិម ដោយមានសិស្សលោកកាន់ចានស្រាក់និងយួរផ្លែឈើដើរតាមក្រោយផង ព្រះអង្គយាងត្រឡប់មកវត្តអ្នកតាសឹងវិញយ៉ាងស្ងប់ស្ងាត់ ។

ទិវារាត្រី ផ្លាស់ប្តូរវេនគ្នាជាធម្មតា ព្រឹកព្រាងនៃថ្ងៃបន្ទាប់

www.elibraryofcambodia.org

ហេតុដ៏អស្ចារ្យមួយកើតឡើងស្ទើរនឹងរកជឿពុំបាន ។ គឺដើមសម៉ីរបស់ឧបាសកសុក មកដុះមុខកុដិព្រះសុគន្ធាមហាថេរហាក់ដូចជាគេដាំទុកតាំងពីច្រើនឆ្នាំមកហើយ ។

មិនត្រឹមតែភិក្ខុសាមណេរក្នុងទីអារាមទេ ដែលនិមន្តមកទតអច្ឆរិយហេតុនេះផ្ទាល់នឹងព្រះនេត្រ សូម្បីអ្នកស្រុកភូមិជិតឆ្ងាយក៏ខំប្រជ្រៀតគ្នាមើលស្ទើរធ្លាយរបងវត្ត ។ នរណាឃើញប្រចក្សហើយ តែងលាន់មាត់ក មិនដាច់ :

- សម្តេចព្រះសុគន្ធាមានបុណ្យណាស់ !
- ព្រះអង្គទ្រង់ប្រកបដោយទិព្វញាណហោ !
- គួរឲ្យកោតបារមីព្រះអង្គមែន !

អច្ឆរិយការណ៍នេះ នាំឲ្យព្រះកិត្តិនាមសម្តេចព្រះសុគន្ធាមហាសង្ឃរាជាគណាធិបតីជិម ល្បីល្បាញសែនឆ្ងាយ ។

www.elibraryofcambodia.org

# វគ្គទី២

# ព្រះរាជសម្ភារ

ពញាតូ ជាព្រះរាជបុត្រច្បងនៃព្រះបាទសម្តេចព្រះជ័យជេដ្ឋា (១) និងអ្នកម្នាងសុខ ព្រះអង្គប្រសូតនៅ គ.ស១៦០១។

លុះព្រះជន្មបាន ២១ វស្សា ព្រះបិតាទ្រង់បង្គាប់ឲ្យរៀបព្យូហនាវាក្បួនធំ នាំព្រះចៅពញាតូចូលបព្វជិតជាភិក្ខុ នៅនគរវត្ត ទើបព្រះជ័យជេដ្ឋាត្រឡប់មកគង់ក្នុងព្រះបរមរាជវាំងវិញ។

សម្តេចព្រះជ័យជេដ្ឋា បានទំនុកបម្រុងព្រះនាងបុប្ផាវត្តី ព្រះរាជបុត្រីឲ្យជាព្រះជាយាកំណាន់នៃព្រះពញាតូ ព្រះអង្គទ្រង់ព្រះចិន្តាថា :

---

១- គួរកត់ចំណាំថា នៅក្នុងរាជ្យស្តេចអង្គនេះហើយ ព្រះចៅក្រុងអណ្ណាមកុកបុរី បានលើកព្រះរាជបុត្រីនាមអង្គចូវថ្វាយជាចំណងព្រះហស្ត ដើម្បីសុំខ្ចីខេត្តកោះក្របី ព្រៃនគរ ៥ឆ្នាំ សម្រាប់បង្គាត់ទាហាន តែតាមពិតយួនមានគំនិតប្រវ័ញ្ចយកទឹកដីនេះរហូតមកដល់សព្វថ្ងៃ ។

www.elibraryofcambodia.org

- កាលណាចៅពញាតូលាចាកសិក្ខាបទមក អញនឹងបង្វែររាជ្យទៅព្រះរាជបុត្រ និងផ្សំផ្គុំព្រះនាងបុប្ផាវត្តីរាជបុត្រី មាតាផ្សេងគ្នាជាព្រះទេពី ដើម្បីកុំឲ្យបែកសម្បត្តិ ។

ឆ្នាំថោះសំរឹទ្ធិស័ក ព.ស ២១៧៩ គ.ស ១៦៣៧ ច.ស ៩៩៩ ព្រះបាទជ័យជេដ្ឋាសោយរាជ្យបានដប់ឆ្នាំហើយ ស្រាប់តែដល់ថ្ងៃ ៣ កើត ខែមិគសិរ ទ្រង់ទិវង្គតទៅក្នុងព្រះជន្ម ៤៩ ព្រះវស្សា ។

ព្រះរាជវង្សានុវង្ស និងនាម៉ឺនសព្វមុខមន្ត្រីលើកព្រះសពតម្កល់ក្នុងកោដ្ឋស្រេច ក៏ជំនុំការផែនដីជាមួយគ្នា :

- ពេលនេះសម្តេចចៅពញាតូព្រះរាជបុត្រច្បងដែលត្រូវទទួលរាជសម្បត្តិពីព្រះវរបិតា ទ្រង់ព្រះផ្នួសនៅឡើយ ។ បើយើងនឹងយាងស្តេចចាកសិក្ខាបទមកឃើញថាពុំគួរ ព្រោះព្រះអង្គកំពុងជាប់អាល័យនឹងធម៌អាថ៌ តើត្រូវគិតបែបណាទៅវិញ ?

- ប្រសិនបើយើងបែរមកយាងព្រះអង្គទូ ឬព្រះអង្គចន្ទដែលជាព្រះអនុជមាតាផ្សេង ឲ្យឡើងគ្រប់គ្រងផែនដីនោះ រីតតែ

www.elibraryofcambodia.org

ខុសនឹងច្បាប់ណាស់ទៅទៀត ដ្បិតព្រះរាជអនុជមិនត្រូវសោយរាជ្យកន្លងព្រះបរមជេដ្ឋាទេ !

- បើដូច្នេះ គួរតែយើងយាងព្រះឧទ័យបរមរាជាមហាឧបរាជវិញ ព្រោះសម្ដេចព្រះបិតុលា ( មាខាងឪពុក) ធ្លាប់កាន់កាប់ការផែនដីស្រាប់ !

- យោបល់នេះប្រពៃហើយ !

- យើងសម្រេចអ៊ីចឹងទៅចុះ !

អស់នាម៉ឺនមុខមន្ត្រីមូលមាត់គ្នាដូច្នេះ ព្រះអង្គនូនិងព្រះអង្គចន្ទបាននាំយកសេចក្ដីជំនុំ ចូលក្រាបបង្គំទូលព្រះមហាឧបរាជតាមដំណើរការណ៍ :

- បពិត្រសម្ដេចព្រះបិតុលា ! ឥឡូវនេះលោកមន្ត្រីគ្រប់តំណែងការសម្រេចជាឯកច្ឆន្ទថា នឹងយាងព្រះអង្គឡើងសោយរាជ្យសម្បត្តិតទៅ សូមទ្រង់ជ្រាបក្រោមល្អងធូលីព្រះបាទ !

- ទូលព្រះបង្គំជាខ្ញុំ មានព្រះទ័យសោមនស្សណាស់ក្រាបទូល !

www.elibraryofcambodia.org

ព្រះឧទ័យជ្រាបសព្វគ្រប់ប្រការ ទ្រង់ព្រះចិន្តាតែមួយអង្គឯងថា :

- កាលសម្តេចព្រះរាជឱង្ការព្រះជ័យជេដ្ឋាជាព្រះរាមគង់ព្រះជន្មាយុនៅឡើយ ព្រះអង្គទ្រង់បម្រុងទុករាជសម្បត្តិនេះថ្វាយពញាតូព្រះរាជបុត្រ ដូច្នេះគប្បីស្អុងជូសតែមួយគ្រាសិនចុះ។ ដល់ក្មួយសិក្ខមកវិញ សឹមបង្វែររាជ្យថ្វាយតាមការគួរ ។

សម្រេចព្រះទ័យយល់ព្រមហើយ មិនយូរប៉ុន្មានព្រះរាជពិធីរាជាភិសេកបានចាប់ផ្តើមឡើងយ៉ាងអធឹកអធម ។ នៅក្នុងទិវាដ៏មហោឡារិកនោះ ព្រះឧទ័យក្រឡេកព្រះនេត្រទៅឃើញព្រះអង្គម្ចាស់ក្សត្រីបុប្ផាវត្តី ដែលសម្តេចព្រះបរមជេដ្ឋាធិរាជកាលនៅគង់ព្រះជន្ម ទ្រង់ផ្គូរផ្គងទុកថ្វាយចៅពញាតូ ព្រះអង្គពេញព្រះទ័យដោយក្តីប្រតិព័ទ្ធយ៉ាងក្រៃលែង ។ ស្តេចខ្វះវិចារណញ្ញាណ បណ្តោយឲ្យអានុភាពនៃសេចក្តីស្នេហា ប្រាសចាកលក្ខណៈថ្លៃថ្នូរគ្របសង្កត់យ៉ាងធ្ងន់ ព្រះអង្គយល់ច្រឡំថា :

- សម្តេចចៅពញាតូលែងចាកសិក្ខាបទហើយ ព្រោះមន្ត្រី

www.elibraryofcambodia.org

ភីលៀង ទូលឲ្យសិក្ខប៉ុន្មានដង តែទ្រង់ពុំយល់ព្រមសោះ ប្រហែលជាស្រឡាញ់ព្រះផ្នូសខ្លាំងណាស់ ។ បើពិតដូច្នោះមែន អញមានផ្លូវអាចចែចូវយកព្រះនាងបុប្ផាវត្តីបានមិនខាន ។

លុះទ្រង់ព្រះចិន្តាមកដល់ត្រង់នេះ ព្រះភ័ក្ត្រសម្តេចព្រះឧទ័យហាក់ស្រស់ស្រាយប្លែកខុសប្រក្រតី ។ ចាប់តាំងពីពេលនោះមក ព្រះអង្គបានចិញ្ចឹមព្រះទ័យស្នេហាលើព្រះនាងបុប្ផាវត្តីស្ទើរគ្មានភ្លេចមួយវេលាណាសោះឡើយ ។

នៅក្នុងព្រះរាជនិវេសនដ្ឋាន ព្រះឧទ័យស្តេចឈ្លក់នឹងតណ្ហាលែងគិតគូរពីកិច្ចការទឹកដីបុរីនគរហើយ ទ្រង់យាងព្រះបាទាចុះឡើងៗ ដោយតប់ប្រមល់ទល់ទុក្ខតែពីរឿងស្នេហាមួយមុខគត់ ។ ព្រះអង្គស្លុងព្រះចិន្តាអស់មួយសន្ទុះ ទើបទ្រង់បន្ទូរខ្យល់អស្សាសៈតាមនាសាឮសូរឃ្មូរយ៉ាងវែង ព្រមទាំងងក់ព្រះកេសាផ្ងក់ៗ ហាក់នឹកឃើញមធ្យោបាយអ្វីម្យ៉ាង ។ ព្រះរាជាត្រាស់នឹងសេវ៉ាកាមាត្យម្នាក់ :

- ចូរឯងទៅហៅនាងចាន់ និងនាងចែម ជាសាវឡិក

www.elibraryofcambodia.org

សំណព្វនៃព្រះអង្គម្ចាស់ក្សត្រីបុប្ផាវត្តីមកណោះមួយភ្លែត !

- សូមទទួលព្រះរាជឱង្ការក្រាបទូល !

ឥតបង្អង់យូរ អាមាត្យថ្វាយបង្គំលានាំអាត្មាចេញទៅក្រៅបាត់ ។ រំលងមួយស្របក់ធំ ទើបលេចមុខមាណវិកាពីរនាក់ ដែលមានរូបសម្បត្តិស្រស់ប្រិមប្រិយ ប្រហាក់ប្រហែលគ្នាដើរចូលមក ដោយក្តីគោរពកោតខ្លាចព្រះចេស្តាស្តេចផែនដី ។ យុវតីទាំងទ្វេ គ្មាននរណាក្រៅពីនាងចាន់ និងនាងចែមទេ សាវ៉ឡិកសំណព្វរបស់ព្រះអង្គម្ចាស់ក្សត្រីបុប្ផាវត្តី ហ្មបហ្មាយថ្វាយបង្គំព្រះនរបតីភ្លាម ។

ទតឃើញហើយ ហ្លួងទ្រង់ព្រះសម្រួលទំនងជាសព្វព្រះរាជហឫទ័យនឹងស្រីសាវ៉ឡិក ដែលចូលគាល់តាមព្រះរាជតម្រាស់ :

- យើងហៅនាងទាំងពីរមក ព្រោះមានការចង់ពិគ្រោះបន្តិច ប្រសិនបើនាងអាចបំពេញកិច្ចការនេះបានសម្រេច យើងនឹងប្រទានរង្វាន់តាប់ចិត្តដល់នាង ម៉េចមើលទៅយល់ព្រមទេ ?

សូម្បីសំណួរនេះ ឋិតក្នុងសភាពការណ៍អាថិកំបាំងយ៉ាង

www.elibraryofcambodia.org

ណាក៏ដោយ ក៏ស្រីស្រស់ទាំងគូប្រាកដជាមិនហ៊ានប្រកែកដែរ ។ នាងចែមឆ្លើយទទួលខ្លួនមុនថា :

- ព្រះករុណាថ្លៃវិសេស ! ទោះបីកិច្ចការនោះលំបាកដូចម្ដេចក្ដី ឲ្យតែព្រះអង្គសព្វព្រះទ័យប្រើមកចុះ ខ្ញុំម្ចាស់នឹងបំពេញថ្វាយរហូតដល់ទីបំផុតនៃជីវិត !

ជាបន្ទាន់នោះ នាងចាន់ប្រញាប់ក្រាបបង្គំទូលយកតាមគូរភ្លាម :

- ឯចំណែកខ្ញុំម្ចាស់វិញ ក៏សូមបម្រើក្រោមល្អងធូលីព្រះបាទដែរ !

- ហាំ ! ហាំ ! ... ប្រសើរណាស់ រង្វាន់ខាន់ខៅនៅរង់ចាំនាងទាំងពីរជានិច្ច ។ ដោយពិតទៅការនោះងាយលើគោកសោះ គឺនាងគ្រាន់តែលួងលោមព្រះអង្គម្ចាស់ក្សត្រីបុប្ផវត្តីយ៉ាងណាឲ្យបាក់ព្រះទ័យមកលើយើងប៉ុណ្ណោះទុកជាការស្រេច !

ព្រះបន្ទូលបំផុសរឿងអាស្រូវរបៀប " ត្រីឆ្កោចង់ស៊ីកូនឯង " ដូច្នេះ ហាក់នាំឲ្យសាវឡិកទាំងទ្វេភ្ញាក់ផ្អើលក្នុងចិត្តបន្តិច

www.elibraryofcambodia.org

ដែរ ប៉ុន្តែមាណវីចាំបាច់រម្ងាប់ទៅវិញ ។ មិនតែប៉ុណ្ណោះសោត នាងចាន់ប្រែទឹកមុខញញឹម ទ្រង់ផ្តល់នូវសេចក្តីសង្ឃឹមយ៉ាងធំ ផង :

- ខ្ញុំម្ចាស់នឹងព្យាយាម បំពេញតាមព្រះរាជបំណងរបស់ ព្រះអង្គលុះត្រាតែបានសម្រេច !

នាងថែមបន្ថែមពីលើប្រយោគមិត្តនារីទៀត ដើម្បីឲ្យ ស្តេចផែនដីកក់ក្តៅទ្វេឡើង :

- សូមព្រះអង្គទុកព្រះទ័យលើខ្ញុំម្ចាស់ទាំងពីរនាក់ចុះ !

គ្រាន់តែឮផ្ទាល់ព្រះកាណ៌ប៉ុណ្ណោះ ព្រះឧទ័យទ្រង់ព្រះសិ- ពាការស្ទើរបិទព្រះឱស្ឋមិនជិត :

- ល្អ ! យើងសង្ឃឹមហើយ កុំភ្លេចចាត់ការឆាប់ៗបន្តិច ណា៎ !

- ព្រះពរ ខ្ញុំម្ចាស់សូមថ្វាយបង្គំលា !

- អើ ! នាងទៅធ្វើការនេះឲ្យបានជោគជ័យកុំបីខាន !

ព្រមទទួលព្រះរាជបញ្ជាហើយ ពុំហ៊ានបណ្តែតបណ្តោយ

www.elibraryofcambodia.org

ទេ  នាងចាន់និងចែមម្ដីមាចូលក្នុងព្រះរាជដំណាក់ព្រះអង្គម្ចាស់ក្សត្រីបុប្ផាវត្តីមួយរំពេច ។

ខណៈនោះ ព្រះនាងបុប្ផាវត្តីកំពុងគង់លើក្រឡាព្រះគំនាល់ ទទួលវាសក្រសែព្រះនេត្រទៅឃើញសាវឡិកសំណព្វ  នាំអង្គប្រាណចូលមកព្រមគ្នា ក្សត្រីសាកសួរថា :

- ឯងទាំងពីរនាក់រវល់ទៅណា ក៏បានអ្នកឯទៀតដើររកមិនឃើញអីចឹង ?

ចំពោះសំណួរនេះ  នាងចាន់និងនាងចែមឥតពិបាកឆ្លើយដោះសាប៉ុន្មានទេ ព្រោះម្នាក់ៗ សុទ្ធតែគិតគូរតាំងពីនាយមកស្រេច :

- ព្រះមែ...ខ្ញុំម្ចាស់អាល័យតែទៅរកបេះផ្កាយកមកក្រងថ្វាយព្រះនាង !

- កម្រងផ្កាភួងនេះស្រស់ទេ ក្រាបទូល ?

មាត់នាងចែមសួរ ដៃទាំងទ្វេលើកកម្រងបុប្ផាឡើងបង្ហាញម្ចាស់ក្សត្រី ដោយទឹកមុខញញឹមលួងព្រះទ័យផង ។

www.elibraryofcambodia.org

កាយវិការដ៏ទន់ភ្លន់របស់សាវឡិក ដែលចេះធ្វើឫកមា-យាដកខ្វីដូច្នេះ ត្រូវព្រះទ័យក្សត្រីណាស់ ព្រះនាងទ្រង់ព្រះសិ- តាការតបវិញ :

- ស្រស់មែន !

ព្រះនាងបុប្ផាវត្តីលាន់ព្រះឱស្ឋដូច្នេះ ព្រមទាំងលាព្រះហស្តទទួលកម្រងផ្កាសិកទៅនឹងព្រះសុរង រួចធ្វើព្រះឥរិយាបថដូចជាឋិតក្នុងវ័យកុមារភាពនៅឡើយ ។

រីឯសាវឡិកសំណព្វទាំងពីរ ដែលមាននាទីចាំតែបញ្ចោរបញ្ចើចបញ្ចើ ក៏នាំគ្នារូតសរសើរក្សត្រីយកសេចក្ដីគាប់គួររៀងៗខ្លួន :

- បើតាមខ្ញុំម្ចាស់យល់ កម្រងផ្កានេះស្រស់មែនហើយ តែពិតជានៅចាញ់ព្រះរូបឆោមលោមពណ៌ព្រះនាង !

- ឱ ! ព្រះនាងស្អាតអ្វីម្ល៉េះទេ តើព្រះអង្គណោមានភ័ព្វវាសនាបានព្រះនាងជាព្រះទេពីហ្ន៎ ?

ពាក្យពេចន៍ហូរចេញមកពីមាត់សាវឡិកបែបនេះ ទ្រង់ធ្វើឲ្យព្រះអង្គម្ចាស់ក្សត្រីអៀនប្រៀនបន្តិចដែរ :

www.elibraryofcambodia.org

- នែ៎ ! ចែមឯងនិយាយអ៊ីចឹងមិនចេះខ្មាសគេទេអ្ហី ?

- នៅក្នុងព្រះរាជដំណាក់ ក្រៅពីខ្ញុំម្ចាស់ពីរនាក់ មាននរណាគួរឲ្យអៀនខ្មាស...

- ក្រែងជញ្ជាំងមានត្រចៀកណា៎ !

នាងចាន់ នាងចែម បែរមើលមុខគ្នាសើចក្អាកក្អាយរួចឆ្លៀតយកឱកាសនោះនឹករកទំនុកវោហារ ដើម្បីស្នើព្រះទ័យក្សត្រី :

- ដោយខ្ញុំម្ចាស់ជឿជាក់ថា ជញ្ជាំងព្រះរាជដំណាក់នេះពិតជាគ្មានត្រចៀកទេ ខ្ញុំម្ចាស់សូមនាំដំណឹងល្អមួយដែលលេចព្លិចល្វេ្យងតាមខ្យល់យកមកថ្វាយព្រះនាងទ្រង់ជ្រាប !

ពោលបង្ហើបតែប៉ុណ្ណេះ នាងចាន់ក៏សម្ងំស្ងៀមទៅវិញជាហេតុបណ្ដាលឲ្យព្រះអង្គម្ចាស់ក្សត្រីបុប្ផវត្តី អត់ទ្រាំនឹងជជីកសួរពុំបាន :

- មើល៍ចាន់ឯងដឹងរឿងអី ប្រញាប់បញ្ចេញភ្លាមមក៍ !

- ប្រសិនបើខ្ញុំម្ចាស់ទូលទៅទាស់នឹងព្រះទ័យហើយ ព្រះ

www.elibraryofcambodia.org

នាងយល់ព្រមអត់ឱនទោសានុទោស ទើបខ្ញុំម្ចាស់ហ៊ានក្រាបថ្វាយការពិត !

- ចាន់និយាយមកចុះ ខ្ញុំសន្យាថាមិនប្រកាន់ប្រកូតអីទេ

រំពេចនោះ នាងចែមធ្វើឫកជាតឿនថា :

- បើព្រះនាងមេត្តាប្រោសហើយ ម៉េចមិនក្រាបបង្គំទូលភ្លាមទៅ នៅរាវែកដល់ណាទៀត ?

បន្ទាប់មក នាងចាន់សម្រួលសេចក្ដីថា :

- ព្រះនាងប្រហែលជាពុំទាន់ជ្រាបទេ ហ្លួងសព្វថ្ងៃទ្រង់សព្វព្រះរាជហឫទ័យនឹងព្រះនាងខ្លាំងណាស់ ព្រះអង្គកំពុងតែចង់លើកតម្កើងព្រះនាងជាព្រះជាយា...

- ឈប់និយាយទៅ ! ចំណាស់ព្រះបិតុលាមានបុត្របីបួនអង្គហើយ តើខំត្រដររមកស្រឡាញ់ក្មួយស្រីឯងយ៉ាងម៉េចទៀត ? ដូចឯងទាំងពីរនាក់ដឹងស្រាប់ ខ្ញុំមានគូកំណាន់ព្រះទ័យហើយពុំមែននៅទំនេរឯណា...!

យល់ថាព្រះអង្គម្ចាស់ក្សត្រីបុប្ផាវត្តី មិនងាយនឹងចុះសម្រុង

www.elibraryofcambodia.org

ផងទេ សាវឡិកទាំងទ្វេត្រូវពនរ្យារពេលផ្លាស់ប្តូរមធ្យោបាយថ្មី ដោយប្រើសម្តីលួងលោមបន្តិចម្តងៗ សមតាមសុភាសិតថា "សន្សឹមកុំបំបោល ក្រែងពុំដល់ដូចប្រាថ្នា" ។ ត្រាតែបានឱកាសល្អមួយ នាងថែមចេះរកឃើញពាក្យពន្យល់ប្លែកជាងសព្វដង :

- ខ្ញុំម្ចាស់ពិតជាស្គាល់ព្រះទ័យស្វាមីភក្តិរបស់ព្រះនាងចំពោះសម្តេចចៅពញាតូចឡើយ ប៉ុន្តែមុខគួរឲ្យស្តាយពន់ពេក ដោយសម្តេចចៅពញាតូច ស្រឡាញ់ព្រះផ្ទុំសប្រុះលហួសរហូតដល់បំភ្លេចព្រះនាង ដែលអ្នកនគរចាត់ទុកថាជាក្សត្រីល្អល្អះគ្មានគូផ្ទឹមទាំងស្រុង តើព្រះនាងសង្ឃឹមលើអ្វី ?

ឆ្លៀតឱកាសនោះ នាងចាក់បណ្តោយតាមក្រោយម្រាក់មួយរំពេច :

- ប្រហែលសម្តេចចៅពញាតូច ពុំមែនគូព្រេងរបស់ព្រះនាងទេ បើពិតដូច្នោះមែន នឹងរាប់ថាសំណាងរបស់ព្រះនាងក៏បានដែរ ព្រោះនៅមានព្រះករុណាជាអម្ចាស់ជីវិតតម្កល់លើត្បូងមួយព្រះអង្គទៀត ដែលសព្វព្រះទ័យចំពោះព្រះនាងគ្មានភ្លេច

www.elibraryofcambodia.org

សោះ ។ គួរតែព្រះនាងទ្រង់ព្រះចិន្តាបន្តិចមើល៍ ក្រាបទូល...!

ដងនេះ ព្រះនាងបុប្ផាវត្តីទ្រង់ទន់ព្រះរាជហឫទ័យក៏គង់នៅស្ងៀមពុំតបតថាដូចម្ដេចឡើយ ។

នាងចាន់ និងនាងថែម យល់ដល់ជម្រៅបេះដូងស្ត្រីខត្តិយត្រកូល នារីទាំងពីរញញឹមមើលមុខគ្នាយ៉ាងមានន័យ ។ លុះទំនេរដៃពីកិច្ចការបម្រើគាល់ហ្វៅក្សត្រីហើយ សាវឡិកទាំងទ្វេក៏នាំយកដំណើងពិសេសនេះទៅក្រាបបង្គំទូលស្ដេច ដែលកំពុងតែរាយមាយនឹងផ្លូវកាមេ :

- សូមទ្រង់ជ្រាបក្រោមល្អងធូលីព្រះបាទ ខ្ញុំម្ចាស់ទូលស្នើព្រះទ័យព្រះនាងក្សត្រីបានសម្រេចហើយ !

និមិត្តតែឮដូច្នេះភ្លាម ព្រះឧទ័យទ្រង់សោមនស្សណាស់:

- ពិតជាអីចឹងមែនអ្ហ ?

- ព្រះពរម្ចាស់ !

ចម្លើយយ៉ាងខ្លី ហើយច្បាស់លាស់ដូចពន្លឺថ្ងៃនេះ នាំឲ្យស្ដេចទ្រង់ក្សេមក្សាន្តក្នុងព្រះទ័យពន់ពេក ព្រះអង្គមិនញញើត

www.elibraryofcambodia.org

ព្រះហស្តនឹងប្រទានរង្វាន់ជាទីគាប់ចិត្តដល់សាវឡិក ដែលដើរតួជាមេអណ្តើកនោះទេ ។

ទិវានេះ សម្តេចព្រះឧទ័យបន់ឲ្យតែយប់ឆាប់ នឹងអាលសម្រេចគម្រោងការដ៏អាស្រូវរបស់ព្រះអង្គ ។ រាត្រីដែលហ្លួងទន្ទឹងរង់ចាំ ហាក់ដូចជាលួនសន្សឹមៗ ចូលមកយឺតយ៉ាវជាងរាល់ថ្ងៃ ។

រត្តិកាលព្រដាងស្បៃខ្មៅគ្របដណ្តប់ភពផែនដី ព្រមជាមួយគ្នានឹងក្រញាំព្រះហស្តស្តេចពាល ដែលឈោងទៅលូកថ្លើមចៅពញាតូព្រះភាគិនេយ្យ ។ នៅក្នុងព្រះក្រឡាបន្ទំព្រះអង្គម្ចាស់ក្សត្រីបុប្ផាវត្តី ព្រះឧទ័យប្រលោមស្នេហ៍ក្មួយស្រីឯងត្រាតែបានសម្រេចតាមព្រះរាជបំណងភ្លើតភ្លើន ភ្លេចគិតអស់ប្រពៃណីអំពីបូរាណ ។

ដោយហ្លួងលង់ក្នុងសមុទ្រតណ្ហាព្រះនាងបុប្ផាវត្តី ទើបទ្រង់តែងតាំងក្សត្រីជាសម្តេចព្រះម៉ែយួរបុប្ផាវត្តី ស្រដីត្រួតត្រាលើព្រះស្នំក្រមការទាំងពួង ។

នេះនឹងថ្លាថ្លែងពីមន្ត្រីភីលៀង ខាងព្រះចៅពញាតូនោះ

www.elibraryofcambodia.org

វិញ ថាតាំងតែព្រះរាជឱង្ការព្រះជ័យជេដ្ឋាធិរាជទ្រង់សុរិយោគត ទៅ ក៏តែងនាំគ្នាយាងពញាតូឲ្យព្រះអង្គចាកសិក្ខាបទមកទទួលរាជសម្បត្តិវិញ ដើម្បីស្ម័គ្របក្សពួកខ្លួនបានចម្រើនយសផង សមដូចពាក្យថា " ចៅហ្វាយឡើងបុណ្យ ខុនឡើងសក្តិ " ។ ប៉ុន្តែឥតប្រយោជន៍សោះ ទោះបីនាម៉ឺនមន្ត្រីភីលៀងសេនា ទទូចសុំជាច្រើនលើកច្រើនសាយ៉ាងណាក៏ដោយ ក៏សម្តេចចៅពញាតូចេះតែប្រកែកដរាប ។

លុះមកដល់ពេលឥឡូវនេះ ព្រះឧទ័យមិនត្រឹមតែឡើងគ្រងរាជប៉ុណ្ណោះទេ ព្រះអង្គថែមទាំងប្រលោមយកក្សត្រីបុប្ផវត្តីទៀត ។ អាស្រ័យដោយមានលេសដូច្នេះហើយ ទើបអស់មន្ត្រីបានពាក្យសម្តីយកទៅក្រាបបង្គំទូលម្តងទៀត :

- ទូលព្រះបង្គំជាខ្ញុំរំឭកព្រះអង្គរឿយៗ ឲ្យចាកសិក្ខាបទទៅទទួលយករាជសម្បត្តិ ប៉ុន្តែទ្រង់បដិសេធពុំព្រមសោះ ពេលនេះសម្តេចព្រះបិតុលាធិរាជកាន់ការផែនដីមួយគ្រាសិន ក៏ពិតមែនហើយ តែទ្រង់បានប្រព្រឹត្តហួសពីនេះគួរឲ្យស្តាយ ដោយស្តេចល្បួងយកព្រះនាងបុប្ផាវត្តី ដែលសម្តេចព្រះវររាជបិតាទ្រង់

www.elibraryofcambodia.org

ផ្លូវផ្គងទុកផ្សំផ្គុំថ្វាយនោះ បានទៅជាព្រះទេពីស្រេចហើយ ។ មិនតែប៉ុណ្ណោះទេ ក្រែងលោបន្តិចទៀត ព្រះបិតុលាទទួលយករាជសម្បត្តិពេញបរិបូណ៌ ដូច្នេះសូមព្រះអង្គទ្រង់ព្រះចិន្តាឲ្យវែងឆ្ងាយបន្តិច !

- ប្រសិនបើព្រះបិតុលាឡើងរាជ្យជាធំហើយ កាលណាឡើយនឹងទ្រង់យល់ព្រមផ្ទេររាជសម្បត្តិ ត្រឡប់ថ្វាយមកព្រះករុណាពិសេសវិញ !

- ថ្វីដ្បិតតែព្រះអង្គជិនឆ្អន់នឹងសិរីរាជសម្បត្តិ ព្រោះហេតុបានប្រព្រឹត្តតាមគន្លងព្រះពុទ្ធសាសនាយ៉ាងណាក៏ដោយ ក៏គួរទ្រង់រេព្រះទ័យគិតដល់ព្រះមាតាដែរ ។ ចុះបើរាជសម្បត្តិឋិតក្នុងកណ្ដាប់ព្រះហស្តសម្ដេចព្រះបិតុលាបែបនេះ មុខនាទីជាសម្ដេចព្រះវររាជមាតា ព្រះទាវ ព្រះកន្លោង នឹងបានទៅខាងព្រះបិតុលាជាពិតប្រាកដ !

- បើនាទីនេះធ្លាក់លើគេហើយ ព្រះអង្គបានកិត្តិយសឯណានឹងថ្វាយសម្ដេចមាតា ? គួរតែព្រះករុណាពិសេសសិក្ខទៅទទួល

www.elibraryofcambodia.org

យករាជសម្បត្តិវិញ ដើម្បីជាកិច្ចតបស្នងព្រះគុណដ៏ធ្ងន់របស់ព្រះមាតាផង !

មន្ត្រីភិលៀងសេនាក្រាបថ្វាយបង្គំ ទូលតឿនព្រះអង្គដូច្នេះច្រើនដង ហើយចេះនិយាយរំលើករហូតដល់ទៅគុណព្រះកន្លោងផង ព្រោះតែចៅពញាតូវទ្រង់ទន់ព្រះទ័យបេ ។

នៅពិធីខាងកើត ខែផល្គុន ឆ្នាំជូត សម្ដេចពញាតូចូលថ្វាយព្រះពរអ្នកម្នាងសុខព្រះមាតា និងសម្ដេចព្រះឧទ័យព្រះបិតុលា :

- អាត្មាមាននិស្ស័យក្នុងភេទជាបព្វជិតតែប៉ុណ្ណេះ ឥឡូវគិតមកលាញោមចាកសិក្ខាបទហើយ !

អ្នកម្នាងសុខថ្វាយបង្គំតប :

- ករុណាឥតយល់ទាស់ទេ !

ឯសម្ដេចព្រះឧទ័យវិញ ព្រះអង្គក៏មិនជំទាស់ដែរ ទ្រង់ត្រាស់ថា :

- ព្រះអង្គយាងមកហើយ បើនឹងត្រឡប់ទៅនគរវត្តវិញ

www.elibraryofcambodia.org

ក៏ឃើញថាយឺតយូរឥតប្រយោជន៍ ។ ជាការប្រសើរ សូមទ្រង់សិក្ខនៅទីនេះទៅ !

- ពរ...តាមព្រះបិតុលាសព្វព្រះទ័យចុះ !

សម្តេចព្រះឧទ័យបរមរាជា ត្រាស់បង្គាប់មន្ត្រីឲ្យរៀបព្រះយានុមាត្យនិងក្បួនដង្ហែព្រះភាគិនេយ្យទៅក្រាបទូលសម្តេចព្រះសុគន្ធាមហាសង្ឃរាជាគណាធិបតីជិម នៅវត្តអ្នកតាសឹងសូមព្រះអង្គប្រទានបាលីចៅពញាតូចាកសិក្ខាបទ ។

លុះស្តេចលាព្រះផ្នួសហើយ ព្រះឧទ័យទ្រង់ព្រះរាជបញ្ជាឲ្យនាម៉ឺន អ្នកមុខ អ្នកការ រៀបគ្រឿងរណ្តាប់រាជាភិសេកថ្វាយរាជ្យសម្តេចចៅពញាតូតទៅ ។ ព្រះឧទ័យបរមរាជា និងមន្ត្រីគ្រប់ក្រសួងក៏តាំងចូលរោងរាជវ័តិប្រារព្ធពិធីតាមប្រពៃណី ។

សម្តេចព្រះសុគន្ធាមហាសង្ឃរាជាគណាធិបតីជិម និងព្រះឧទ័យ ព្រមទាំងព្រះរាជគ្រូបុរោហិត ស្រោចទឹកឃោងព្រះកេសព្រះអង្គតូ ទ្រង់ព្រះខ័នព្រះនារាយណ៍ថ្វាយព្រះបរមនាមថា " ព្រះបាទសម្តេចព្រះរាជឱង្ការ ព្រះស្រីធម្មរាជាធិរាជ រាមា

www.elibraryofcambodia.org

ធិបតី " ប៉ុន្តែពង្សាវតារកំណត់ព្រះនាមត្រឹមតែព្រះស្រីធម្មរាជា ឬព្រះរាជសម្ភារ ។

នៅក្នុងរាជ្យនេះ ស្តេចផែនដីទ្រង់បានផ្លាស់រាជស័ព្ទដែលព្រះរាជាមុនៗ ធ្លាប់កែប្រែជាច្រើនដងហើយនោះ ដោយសព្វព្រះរាជហឫទ័យឲ្យមន្ត្រីតូចធំឆ្លើយឆ្លងនឹងព្រះអង្គថា " ព្រះរាជសម្ភារបារមីពិសេស "។ ចំពោះសម្តេចព្រះទាវធីតាសុខជាព្រះមាតាថា " បារមីពិសេស " ឯព្រះឧទ័យព្រះបិតុលាកុំឲ្យថា "ព្រះភូវនាថ " ។

គិតៗទៅស្តេចគ្រប់អង្គមិនជាជាងគ្នាប៉ុន្មានទេ រឿងលើកតម្កើងឫទ្ធីបារមីចេស្តា ឲ្យអាណាប្រជានុរាស្ត្រកោតសរសើរមានខ្លះចង់តាំងខ្លួនរហូតដល់ទៅតួអង្គទេវបុត្រ ច្យុតមកចាប់បដិសន្ធិនា ឋានកណ្តាលនេះថែមទៀតផង ។ ប៉ុន្តែតាមពិតសុទ្ធសឹងជាមនុស្សក្បាលខ្មៅទាំងអស់ ដូច្នេះការអាក្រក់ល្អស្រេចនូវលើអំពើដែលបុគ្គលម្នាក់ៗបានប្រព្រឹត្ត នៅក្នុងដំណើរជីវិតតែប៉ុណ្ណោះ ។

www.elibraryofcambodia.org

ចាប់តាំងពីឡើងសោយរាជ្យសម្បត្តិមក ព្រះរាជសម្ភារ ទ្រង់ចេះតែបារម្ភ ក្រែងសម្ដេចព្រះបិតុលារង្កៀសព្រះទ័យព្រះ អង្គឯងពីរឿងព្រះម៉ៃយូរបុប្ផាវត្តី ។ ហេតុនេះហើយទើបទ្រង់ តប់ប្រមល់ណាស់ ក៏ត្រាស់ឲ្យមន្ត្រីមុខងាររៀបចំព្រះទីនាំងនាវា ជាសម្រេច ស្ដេចយាងចុះគង់កណ្ដាលនាម៉ឺនមន្ត្រីសេនាសេវ-កាមាត្យចេញព្រះរាជដំណើរទៅក្រសាលឯស្រុកទន្លេធំ ។

កាលយាងដល់កោះឃ្លោក (១) ទន្ទឹមនឹងត្រើយជ្រោយ មេត្រី ព្រះអង្គបង្គាប់ឲ្យចូលចតព្រះទីនាំង ។ ស្ដេចទតព្រះនេត្រ ឃើញទីទួលផ្ទាក់ផ្ទល់ធំទូលាយ ប្រកបទៅដោយខ្សាច់ផូរផង់ល្អ ហើយដីក៏រាបស្មើគួរចាប់អារម្មណ៍ ទ្រង់ឈ្វេងយល់ថា :

" គួរតាំងព្រះនគរនៅលើទឹកដីនេះ នឹងបានសុខក្សេមក្សាន្តប្រាសចាកមន្ទិលសៅហ្មងមិនខានឡើយ " ។

ព្រះរាជសម្ភារឈប់សម្រាកព្រះកាយពល ក្រសាលមួយរយៈ ទើបស្ដេចត្រឡប់មកកាន់ព្រះរាជវាំងវិញ ។

---

១- គឺនៅក្នុងស្រុកខ្សាច់កណ្ដាលសព្វថ្ងៃនេះ ។

www.elibraryofcambodia.org

ខែអាសាធ ឆ្នាំខាលសំរឹទ្ធិស័ក ព.ស ២១៨២ គ.ស ១៦៣៨ ច.ស ១000 មន្ត្រីក្រុមសុរិយោដី និងមេការជាងឈើ យកសេចក្តីក្រាបបង្គំទូលថា :

ទូលព្រះបង្គំជាខ្ញុំទាំងអស់គ្នា បានសាងព្រះរាជវាំងកោះឃ្លោកនេះរួចស្រេចហើយ...!

- យើងអរគុណអស់លោក ដែលខិតខំធ្វើការនេះខ្លាំងណាស់ !

- ព្រះរាជសម្ភារបារមីពិសេស...

បន្ទាប់ពីទ្រង់បានជ្រាបការនេះសព្វគ្រប់ ព្រះរាជសម្ភារថ្វាយបង្គំលាមាតា និងសម្តេចព្រះបិតុលាលើកអស់ទាំងរាជសេវកាក្សត្រាក្សត្រីក្នុងក្រៅទៅគង់នៅព្រះរាជវាំងកោះឃ្លោក ។

ព្រះរាជឱង្ការព្រះស្រីធម្មរាជាឬព្រះរាជសម្ភារ ទ្រង់ចេះចាំព្រះត្រៃបិដកធម្មច្បាស់លាស់ណាស់ សោតទាំងគតិលោកគតិធមិក៏ដូច្នោះដែរ ។ ព្រះអង្គជាកវីនិពន្ធដែលមានស្នាព្រះហស្តក្នុងការតាក់តែងកំណាព្យកាព្យឃ្លោង ទុកជាច្បាប់សម្រាប់អ្នកនគរត្រិះរិះពិចារណា ។

www.elibraryofcambodia.org

សម័យថ្ងៃមួយនោះ ព្រះរាជសម្ភារត្រាស់បញ្ជាឲ្យក្រុមព្រះរាជក្រិត្យសង្ឃការី ទៅនិមន្តសម្ដេចព្រះសុគន្ធាមហាសង្ឃរាជាគណាធិបតីជិម គង់ព្រះទីនាំងនាវាទៅប្រពាតក្នុងបឹងស្រុកច្រណូក[១] ។

លុះក្រសាលអស់ពេលជាច្រើនថ្ងៃមក ស្ដេចផែនដីទ្រង់ទឹកភ្នែកដល់ព្រះម្នាងទា ព្រះអង្គយករលាដូងដាក់ស្លាបទាមួយរួចបណ្ដែតទៅរកព្រះទីនាំងនាវានៃព្រះសុគន្ធាមហាថេរ ដើម្បីធ្វើការពិសោធន៍ក្នុងកុលកិច្ចជាអាថ៌ប្រស្នា ។

ពេលនោះ សម្ដេចព្រះសុគន្ធាទតឃើញហើយ ក៏ប្រាប់សិស្សានុសិស្សទាំងឡាយថា :

- ហ្លួងច្បាស់ជាត្រឡប់ទៅព្រះរាជវាំងក្នុងថ្ងៃនេះវិញពុំខាន ។

ដោយទឹកមិនដល់ប្រស្នាអាថ៌កំបាំង សិស្សានុសិស្សក្រាបទូលសួរថា :

១- ឥឡូវនេះក្លាយមកជាភូមិតូចមួយក្នុងស្រុកកំពង់លែង ខេត្តកំពង់ឆ្នាំង ។

www.elibraryofcambodia.org

- ហេតុដូចម្ដេចបានជាសម្ដេចទ្រង់ជ្រាប ?

សម្ដេចព្រះសុគន្ធាមហាសង្ឃរាជា លើកព្រះហស្ដចង្អុលទៅក្នុងបឹង ព្រមទាំងមានព្រះបន្ទូលបកស្រាយជាបន្ទាន់ :

- អ្នកទាំងអស់គ្នាឃើញទេ ហ្លួងទ្រង់បណ្ដែតរលាដូង និងស្លាបទាមកនោះ ជាអាថ៌ប្រស្នាបានសេចក្ដីថាវែងថា រលាដូងបណ្ដែតទឹក បើនិយាយកាត់ឲ្យខ្លីរលាទឹក ប្រែថារលឹកអ្នកម្នាងទាណាស់ ដូច្នេះស្ដេចនឹងត្រឡប់ទៅក្រុងវិញក្នុងពេលឥឡូវនេះហើយ !

ព្រះសុគន្ធាមហាថេរ ដោះប្រស្នានេះពុំទាន់ផុតពីព្រះឱស្ឋផង ស្រាប់តែសេនាចែវព្រះទីនាំងវាយគងទូងស្គរ ប្រាប់នាម៉ឺនមុខមន្ត្រីដែលហែហមជាបរិវារមកទាំងប៉ុន្មាន ឲ្យដកយុថ្កាស្រាវពួរពាក់ចែវគ្រប់ៗគ្នាភ្លាម ។

ហេតុការណ៍ពិតជាក់ស្ដែងជាបន្ទាន់ក្នុងពេលនេះ នាំឲ្យសិស្សានុសិស្សសន្មតក្នុងចិត្តថា :

- សម្ដេចព្រះសុគន្ធាមហាសង្ឃរាជាគណាធិបតីដើម មានបុណ្យទិព្វញ្ញាណលើសលែងអស់មនុស្សផង ។

www.elibraryofcambodia.org

# វគ្គទី៣

## ភ្លើងឆេះក្រុងចិន

ថ្ងៃមួយនោះ សម្ដេចព្រះសុគន្ធាមហាសង្ឃរាជាគណា-ធិបតីជិម យាងចូលសមាបត្តិ កាលចេញចាកឈាននោះមកវិញ ព្រះអង្គមានថេរដីកាប្រាប់សិស្សានុសិស្ស និងសទ្ធិវិហារិក[១] ថា:

- ឥឡូវនេះភ្លើងកាចឆាបឆេះក្រុងចិនសម្បើមណាស់ !

ជនទាំងពួងឮដូច្នេះហើយ ខ្លះក៏ជឿជាក់ ឯខ្លះទៀតមិនទុកចិត្តថាមែនទេ ព្រោះដូចជាហួសនិស្ស័យពេក ។

វេលានោះ ព្រះសុគន្ធាធិបតីយកទឹកផ្តិលមកបាចសាចតម្រង់ទៅទិសស្រុកចិនមួយរំពេច ព្រមទាំងបើកព្រះឱស្ឋតិចៗល្មមស្តាប់ឮ :

---

១- អ្នកនៅជាមួយ គឺភិក្ខុឬសាមណេរ ដែលជាសិស្សរបស់ឧបជ្ឈាយ៍ត្រូវនៅក្នុងអំណាចឧបជ្ឈាយ៍ ឲ្យលោកមើលការខុសត្រូវស្តីប្រដៅជានិច្ច ។

www.elibraryofcambodia.org

- អាត្មាជួយលត់ភ្លើងស្រុកចិនសិន !

គឺជាការពិតណាស់ បើយើងងាកទៅមើលក្រុងចិន ឯណោះវិញ អគ្គីភ័យកំពុងតែឈៀនអណ្តាតភ្លើងភ្លែម១ យ៉ាងសន្ធោសន្ធៅ ។ ទោះបីស្តេចចិនចាត់កងពលសកលយោធាឲ្យពន្លត់វារ [illegible]ណាក៏ដោយក៏ពុំឈរទេតោះ ។ អស់តេជះ [illegible] ក្រុង [illegible] ដឹងថាការលោតឡើងព្រះពន្លឺអគ្គីឆេះតាមអំពើវា ។ ព្រះអង្គទម្លាក់ព្រះភ័ក្ត្រជ្រប់ ដោយបម្រុះព្រះតម្រិះ[illegible] មកថា :

- អស់សង្ឃឹមហើយ យើងគ្មានមធ្យោបាយឯណានឹងការពារទីក្រុងមិនឲ្យក្លាយទៅជាផេះបានទេ !

គួរអស្ចារ្យពន់ពេក អគ្គីភ័យដែលកំពុងឆេះវាតទីពេញបន្ទុក ស្រាប់តែរលត់ព្រមគ្នាទៅវិញ ហាក់បីដូចគេលត់ភ្លើងទៀនឬគោម ។ យល់ហេតុចម្លែកដូច្នេះ ស្តេចក្រុងចិនត្រាស់នឹងទាហានរក្សាព្រះអង្គថា :

- ចូរឯងទៅហៅហោរាមកណោះមួយភ្លែតមើល៍ !

ហោរាចិននោះលុតជង្គង់ចុះ ឱនក្បាលផ្តុំដៃទាំងពីរលើកប្រណម្យ :

www.elibraryofcambodia.org

- សូមគោរពព្រះរាជឱង្ការព្រះករុណាជាអម្ចាស់ !

នាយទាហានថយចេញទៅបាត់មួយសន្ទុះ ក៏លេចមុខតាចាស់ម្នាក់ឋិតក្នុងសម្លៀកបំពាក់វែងតយារ ស្ទើរលប់ដៃជើងបាត់អស់ បោះជំហានទ្រើកៗ ចូលមកចំពោះព្រះភ័ក្ត្រព្រះរាជា គ្មាននរណាក្រៅពីហោរាប្រចាំការក្នុងវាំងទេ ។

បន្ទាប់ពីធ្វើគារវកិច្ចតាមទំនៀមមិនរួចហើយ តាហោរាងាករកកន្លែងគួរសម ដើម្បីរង់ចាំស្ដាប់ព្រះរាជឱង្ការស្ដេចផែនដី។

ព្រះភូបាលយកព្រះហស្តច្បូតព្រះមស្សុ (ពុកមាត់) បន្ទិច :

- តាហោរា !

- ព្រះករុណាថ្លៃវិសេស !

- យើងអញ្ជើញតាមកក្នុងពេលនេះ ព្រោះចង់ឲ្យតាទស្សន៍ទាយមើល៍ តើមានហេតុភេទយ៉ាងណា ទើបភ្លើងឆេះទីក្រុងយើងរលត់ទៅវិញដោយឯកឯងអ៊ីចឹង ?

- ទូលព្រះបង្គំជាខ្ញុំសូមទទួលព្រះរាជឱង្ការ ក្រាបទូល !

រំពេចនោះ ហោរាចិនបញ្ចេញក្ដារឆ្នួនមក កាន់ដីសរាងបញ្ឈរគូរវាសវាយលេខអត្ថ: ឃើញក្រវេមក្រវាមដូចជើងក្ដាម :

www.elibraryofcambodia.org

- បពិត្រព្រះអង្គដ៏ចម្រើន ! បើតាមដើងលេខឆ្លើយថា អគ្គិភ័យដែលរលត់ឯង១ដូច្នេះ ព្រោះមានព្រះសង្ឃមួយអង្គនៅក្នុងខេមរប្រទេស ព្រះទ័យប្រសើរវិសេស ជួយលត់ភ្លើងកាចចង្រៃនេះ !

កាលបើឮហោរាទាយបែបច្បាស់ពេក ស្ដេចក្រុងចិនទៅជារបូតសួរសៀងថា :

- យី ! អីក៏ចម្លែកម្ល៉េះហ្ន៎ ?

ឋិតក្នុងសភាពស្ងប់ស្ងាត់មួយសន្ទុះ ទើបព្រះរាជាទ្រង់ប្រឹក្សានឹងនាម៉ឺនសព្វមុខមន្ត្រី :

- ចំពោះហេតុការណ៍ ដែលហោរាទស្សន៍ទាយមកនេះ តើអស់លោកមានយោបល់យ៉ាងណាដែរ ?

នាម៉ឺនម្នាក់ទ្រង់ចាស់ទុំជាងគេ បន្ទន់កាយផ្គុំដៃគោរពក្រាបបង្គំទូលមួយ១ :

- ទូលព្រះបង្គំយល់ឃើញថា គឺប្រាកដជាការពិតឥតប្រកែកបានទេ ព្រោះតាំងពីដើមរៀងមក លោកហោរាចារ្យនេះ តែងទាយថ្វាយព្រះអង្គត្រូវជំនាញចំណោប់ណាស់ មិនដែលខុសម្ដងណាសោះ !

www.elibraryofcambodia.org

- យើងធ្លាប់ទុកព្រះទ័យលើតាហោរាអ៊ីចឹងដែរ តែម្ដងនេះទំនាយរបស់គាត់ដូចជាចម្លែកពេក !

ខណៈនោះមន្ត្រីម្នាក់ស្លៀកពាក់របៀបអ្នកចម្បាំង ធ្វើវន្ទនកិច្ចរួចហើយ ក៏បញ្ចេញសម្ដីភ្លាម :

- បើចង់ដឹងការពិតថា តាហោរាទាយត្រូវឬខុស គប្បីបញ្ជូនរាជទូតទៅស៊ើបមើលឯក្រុងកម្ពុជាធិបតី ច្បាស់ជាបានដឹងជាក់មិនខាន !

អង្គប្រជុំទំនងយល់ស្របឥតទាស់ :

- យោបល់នេះប្រសើរហើយ !

ស្ដេចមិនងក់ព្រះកេសផ្ងក់ៗ ព្រះអង្គសម្រេចសេចក្ដីថា :

- មែន ! ត្រូវតែចាត់រាជទូតទៅកាន់ខេមរប្រទេសយ៉ាងឆាប់បំផុត ប្រសិនបើស៊ើបសួរដឹងថាពិតដូចទំនាយហោរាហើយ យើងចាំបាច់តបស្នងសងព្រះគុណព្រះសង្ឃអង្គនោះ ឲ្យបានពេញព្រះទ័យ !

- ព្រះរាជតម្រិះរបស់ព្រះអង្គប្រពៃណាស់ !

www.elibraryofcambodia.org

បន្ទាប់មក ស្ដេចក្រុងចិនត្រាស់សួរឡើងថា :

- អស់លោកទាំងបី ដែលទទួលតំណែងជារាជទូត ឧបទូត និងត្រីទូត មានមករួមប្រជុំក្នុងទីនេះទេ ?

បុរសម្នាក់មាឌធំដំបងពាក់មួកកំពូលស្រួច ប្រដាប់ដោយអាវក្រោះដៃខ្លី ខោព្រៃផ្កាលើបរលោង ត្រូវនឹងស្បែកជើងសំពត់ពណ៌ខ្មៅសុទ្ធ ក្រោកឈរឡើងងាកមើលឆ្វេងស្ដាំបន្តិច រួចឱនកាយលើកកំបង់អញ្ជលីតាមរបៀបចិនមួយរំពេច :

- ក្រាបទូលមកជួបជុំគ្នាអស់ហើយ !

- ល្អ ! ចូរលោកទាំងបីប្រុងប្រៀបរៀបចំខ្លួនឲ្យហើយ តាំងពីឥឡូវនេះទៅ កាលណាមានជើងសំពៅជំនួញទៅកាន់នគរខ្មែរ លោកត្រូវរូតរះចេញដំណើរភ្លាម !

- ទូលព្រះបង្គំជាទូតានុទូតទាំងអស់គ្នា សូមទទួលព្រះរាជបញ្ជាល្អងធូលីព្រះបាទ !

រំលងប៉ុន្មានថ្ងៃក្រោយមក រាជទូត ឧបទូត និងត្រីទូត នាំគ្នាចុះភេត្រា បំណងមកកាន់ដែនសីមាក្រុងកម្ពុជាធិបតី ។

www.elibraryofcambodia.org

សំពៅថយចេញពីកំពង់ផែ បែរក្បាលបើកក្ដោងលូនលយ កាត់ផ្ទៃជលសាគរឆ្ងាយទៅៗ ។ អ្នកដំណើរនៅក្នុងនាវាទាំងអំបាលម៉ាន ចោលភ្នែកក្រឡេកមើលកោះត្រើយជាត្រាបង្ហើយ ។ ចំពីមុខគេឃើញតែទឹកជាប់នឹងមេឃ គួរឲ្យលន្លង់លន្លោចចិត្តអ្វីម្ល៉េះទេ ។

ទូតទាំងបីអង្គុយដាច់ឆ្ងាយគេឯង ចាក់ទឹកតែផឹកជជែកគ្នាលេងលាយឡំនឹងសំឡេងអ៊ូអរពីដំបូងទី ហើយស្ងូរមាត់មនុស្សទាំងអស់ចេះតែចុះខ្សត់ខ្សោយទៅវិញ នៅពេលដែលភេត្រាចេញចាកឆ្ងាយផុតដែនគោក ។

ការធ្វើដំណើរតាមផ្លូវទឹកនេះ បានពេញមួយថ្ងៃមួយយប់ហើយ ព្រលឹមឡើងនៃទិវាថ្មី រស្មីម៉តអើតចេញមកតាមចន្លោះជើងមេឃនាបូព៌ាទិស ឆ្លុះប្រុះស្រមោលលឿងឆ្អិនឆ្អៅទៅក្នុងជលសា មើលមួយក្រឡេកសឹងប្រៀបបាននឹងលោហិតស្រស់ៗ ។

ខណៈនោះ សូរស័ព្ទស្មែងរសាត់តាមខ្យល់មកពីចម្ងាយគួរឲ្យព្រឺក្បាល ។ អ្នកដំណើរទាំងឡាយណា ដែលធ្លាប់ចុះស្មាម

www.elibraryofcambodia.org

តាមផ្លូវជើងទឹកច្រើនដងហើយ ហាក់ភ្ញាក់ផ្អើលជ្រួលច្របល់ក្នុងចិត្តយ៉ាងខ្លាំង ។ ម្នាក់ៗភ្នែកសេក ភ្នែកលលក ងាករកមើលចុះឡើង ក៏ប្រទះឃើញជលយានមួយខ្មៅទទុងកំពុងលូនសន្សឹមៗមកពីនាយ ទំនងជាតម្រង់រកសំពៅគេតែម្តង ។

មួយស្របក់ធំក្រោយមក សំឡេងស្នែងទីពីរ...រួចទីបីក៏បន្លឺឡើងបន្ទាប់គ្នា ។ អ្នកជំនួញទាំងឡាយកាន់តែភ័យបុកពោះមែនទែន តែគ្មាននរណាបញ្ចេញវាចាថាដូចម្តេចទេ ។ គេនៅឈរស្ងៀមធ្មឹងប្រៀបបាននឹងរូបចម្លាក់ ដោយផ្តោតក្រសែចក្ខុជាប់នឹងសំពៅចម្លែក ស្ទើរពុំហ៊ានប៉ប្រិចសោះឡើយ ។

មិនយូរប៉ុន្មាន ភេត្រាមកពីដែននាយបង្ហាញឲ្យឃើញទង់ធំរូបនាគបក់រវិចៗតាមកម្លាំងវាតា ។ យល់ជាក់នឹងភ្នែកដូច្នេះហើយ អ្នកខ្លះភ័យតក្កមាជាខ្លាំង រកកលនឹងភ័ន្តភាំងមួយរំពេច ខ្លះទៀតស្មារតីរឹងប៉ឹង ខំប្រឹងស្រែកប្រាប់គ្នីគ្នាតែសព្វខ្លួន ៖

- សំពៅចោរ !

- ពួកនាគសមុទ្រនេះ ឮល្បីថាកាចសាហាវណាស់ យើង

www.elibraryofcambodia.org

មិនត្រូវតែក់ស្លុតទេ អាសន្នអន់ក្រនឹងឈានចូលមកដល់ឆាប់ៗនេះហើយ ដូច្នេះចាំបាច់ប្រុងប្រយ័ត្នឲ្យមែនទែន ឬមួយយើងសុខចិត្តបណ្ដោយឲ្យទឹកចូលច្រមុះស្លាប់រសាត់ឥតការ ?

- ប្រញាប់ចាប់អាវុធគ្រប់ដៃភ្លាម បងប្អូន !

ដោយពិតទៅអ្នកដើរសំពៅ ធ្វើជំនួញជួញប្រែឆ្លងកាត់ទឹករាប់ខែឆ្នាំ ភាគច្រើនដាច់ខាតតែងមានចិត្តក្លាហាន ហើយអំណត់ធន់ថែមទៀតផង ។ មិនតែប៉ុណ្ណោះសោតតេពុំមែនជាមនុស្សដំឡូងមូលទេ ម្នាក់ៗហោចណាស់ក៏ចេះវិជ្ជាគុនកាន់អាវុធគ្រាន់នឹងការពារខ្លួនក្នុងគ្រាអាសន្នម្ដងម្កាលដែរ ។ ប៉ុន្តែច្បាស់ជាមិនខ្វះគ្រូគុន ដែលរកស៊ីធានារ៉ាប់រង របស់មានតម្លៃផ្សេងៗព្រមមួយអន្លើដោយសិស្សគណផងទេ ។

សភាពប្រុងជើងការ បានរៀបចំស្រេចបាច់ហើយនៅក្នុងពេលនេះ អ្នកជំនួញជួញដូរទាំងឡាយ នឹងអាតួហ៊ាររកស៊ីលីដាវចិញ្ចឹមជីវិតខ្លះទៀត ទំនងឋិតនៅក្រោមបញ្ជាគ្រូគុនម្នាក់អាយុប្រមាណហាសិបប្លាយឆ្នាំ រាងរៅមាំទាំ ត្រូវនឹងសម្បៀកបំពាក់

www.elibraryofcambodia.org

បែបរលុង រីតតែឃើញមាឌធំលើសពីធម្មតា ។ មុខវែងពុកមាត់ពុកចង្កាស្កូវល្បាយអាចម៍ខ្លា ស្រស់ត្រង់មូកដាំអង្កាំ ។ គាត់ឈរទន្ទឹងរង់ចាំមើលហេតុការណ៍ផ្សេងៗ ហាក់គ្មានតក់ស្លុតរន្ធត់ក្នុងចិត្តសោះឡើយ ។ គ្រូគុនងាកទៅនិយាយនឹងសិស្សគណមួយចំនួនថា :

- យើងជាជួរមុខមានវិន័យយ៉ាងណា ព្រោះថាបើស្លាប់ទៅជាខ្មោច កុំឲ្យតែសល់កេរ្តិ៍អសោចិ៍ដល់ក្រុមធានា ម៉េចស្តាប់បានទេ ?

- បាទលោកគ្រូ យើងខ្ញុំទាំងអស់គ្នាយល់នាទីរបស់ខ្លួនច្បាស់ហើយ !

- គ្រូសុំអរគុណទុកជាមុន !

មានវាចានឹងសិស្សតែប៉ុណ្ណោះ មេក្រុមធានាដើរចូលមកសម្តែងការគួរសមជាមួយទូតទាំងបីបន្តិច :

- រាប់ថាភ័ព្វសំណាងណាស់ដែរ ដែលបានអស់លោករួមដំណើរមកក្នុងពេលនេះ យើងខ្ញុំសូមផ្ញើសេចក្តីសង្ឃឹមមួយភាគធំផង !

www.elibraryofcambodia.org

រាជទូតញញឹមបន្ទន់កាយគោរពតបវិញ ទន្ទឹមនឹងពាក្យទទួលថា :

- នៅក្នុងសំពៅតែមួយ បើម្នាក់ៗមិនខិតខំជួយការពារទេ ហើយបណ្តោយឲ្យលិចលង់ទៅតាមយថាហេតុ យើងក៏ពុំអាចរស់ឃើញពន្លឺថ្ងៃកើតដែរ !

រំពេចនោះ ឧបទូតនិយាយបន្តក្នុងន័យក្រើនរំឭក :

- កាលៈទេសៈបែបនេះ ត្រូវតែបង្ហាញឲ្យឃើញកម្លាំងសាមគ្គីធមិ !

ត្រីទូតឧទានឡើង ទ្រង់ចង់លើកទឹកចិត្តអ្នកឯទៀត :

- បងប្អូនយើងមួយសំពៅប្តូរស្លាប់ រស់ រួមគ្នាហើយ !

ឥឡូវនេះ ជលយានមានទង់សញ្ញារូបនាគដ៏កាចសាហាវដែលអ្នកជំនួញជួញប្រែជើងចាស់ស្គាល់ច្បាស់ជាសំពៅចោរ លូនសសៀរមកកាន់តែជិតឡើងៗ គួរឲ្យបារម្ភទុកក្នុងពោះ ។

រំលងប្រហែលមួយអន្ទាំស្លា ភេត្រាទាំងពីរចូលកៀកកិតស្ទើរប៉ះទង្គិចគ្នា ព្រោះអ្នកកាន់ចង្កូតនាវាទង់នាគ កាច់ក្បាល

www.elibraryofcambodia.org

តម្រង់មក បែបរាងទទឹងទិសតាំងពីចម្ងាយ ។ សម្រែកហៅ កញ្ជ្រៀវរបៀបព្រៃផ្សៃ ផុះឡើងកក្រើកទឹក ដំណាលគ្នានឹង អាត្មាចោរសមុទ្រ ហក់លោតជើងពីរ ជើងបីឆ្លងមកកាន់សំពៅ ជំនួញ ហាក់មានអំណាចមិនខ្លាចស្លាប់មុនអាយុសោះឡើយ ។

ជនទ្រើសឃ្នងម្នាក់ មាឌធំដំបង វិស័យកូនកាត់យក្ស ស្លៀកពាក់ខោអាវពណ៌ក្រហម ប្រៀបបានទឹងអណ្ដាតភ្លើងនរក មុខក្រញូវ មាត់ដូចគេពេប ចិញ្ចើមទាំងគូវាត់ឡើងលើ មើល មួយភ្លែតស្មានច្រឡំថាក្បាលទីងមោងគួរនឹងគួទន្ទ្រាំងដី ។ បើ តាមឫកពា អាត្មាហ៊ានេះទំនងជាមេកោយត្រួតត្រាគេឯងទាំងអស់ ទើបវាហ៊ានលើកដៃស្ដាំកាន់ដាវក្នុងស្រោម វាឃាត់បក្សពួកយ៉ាង ខែងរ៉ែង :

- ពួកឯងនៅស្ងៀមសិនចុះ ទុកពេលឲ្យអញចរចានឹងគេ មួយភ្លែត !

បន្ទាប់ពីខ្ជាក់សម្ដីដូច្នេះហើយ មនុស្សពាលរលាក់សំណើច ក្អាកក្អាយទ្រង់ប្រមាថកាតទានអ្នកទាំងឡាយថា មិនដល់ខ្លួនទេ

www.elibraryofcambodia.org

តែបោះជំហានទៅមុខមួយៗបែបធ្ងន់ពារ់ រួចទច់នៅមួយកន្លែង លើកដងដាវចង្អុលមុខគ្រូគុនភ្លាម :

- កញ្ចាស់ចោលស្រុកឯងជាមេក្រុមធានាមែនទេ ?

បុរសចំណាស់ឈរជ្រែងតក្កេធ្វើហាក់វាហី :

- ចុះបើយើងឆ្លើយថាមែន តើវាយ៉ាងម៉េចទៅវិញ ?

- ពៅ ! ពៅ ! អញចង់ឲ្យឯងសារភាពត្រង់ៗអ៊ីចឹងទើប ស្រួលនិយាយគ្នាតែប៉ុណ្ណឹងទេ !

ពោលពាក្យតំរោះតំរើយមកដល់ត្រឹមនេះ ទទួលក្រឡេកភ្នែកទៅឃើញទូតានុទូត មហាចោរធ្វើឫកជាងក់ក្បាលគោរពបន្តិចយ៉ាងសោះកក្រោះ :

- អូ ! ស្មានមិនដល់សោះថា មានអស់លោកខាងទីក្រុងពីរបីនាក់អញ្ជើញមកដែរ សូមអភ័យទោស ! ដូច្នេះបានសេចក្តីថានៅក្នុងហ្វូងចៀមនេះ ក៏តង់ច្រឡំបល់ទៅដោយសត្វខ្លាកំបុតកន្ទុយខ្លះ ដែលកំពុងតែលាក់ក្រចក ។ ប៉ុន្តែទោះបីចុះទៅក្នុងទឹកឃើញល្មោងក្រពើ ឡើងលើប្រទះនឹងភ្នំខ្លាយ៉ាងណា ក៏ដោយ

www.elibraryofcambodia.org

ក៏ក្រុមនាគសមុទ្រមិនដែលនឹកញញើតញញើមដែរ ព្រោះមុខរបររបស់អញតែប៉ុណ្ណឹងទៅហើយ !

មេចោរងាកមកនិយាយនឹងគ្រូគុនវិញយ៉ាងព្រហើន :

- ខ្លួនចាស់គួរតែសម្រាកទុកវេនហក់លោតឲ្យក្មេងៗម្តង តែមិនរំពឹងទេ កញ្ចាស់ឯងត្រូវឲ្យគេដើររកស៊ីចិញ្ចឹមក្រុមគេដោ មុខគួរស៊ីខ្មាស !

- អាចោរចង្រៃឯងគ្មានសិទ្ធិអីមកត្រួតត្រាអំបែងក្បាលយើងទេ !

- ចាស់ហើយ នៅចិត្តខ្លាំងដូចភ្លើងទៀត ពិចថាងាប់ចោលម្សៀតណាំ ! បើចង់សុខខ្លួនទាំងអស់គ្នាគ្រាន់នឹងបានវិលទៅជួបមុខប្រពន្ធកូនវិញ ត្រូវតែប្រគល់របស់របរក្នុងសំពៅនេះ ឲ្យដល់ក្រុមនាគសមុទ្រដោយស្រួលៗមក៏ !

នាយពាណិជម្នាក់ ដែលឈរប្រុងពីមុខគេឯងបន្លឺសម្រែកទាំងក្តៅក្រហាយ :

- ហ៊ឹះ ! ទម្រាំនឹងបានអីវ៉ែអីវ៉ាន់យកមកជួញប៉ុណ្ណេះ

www.elibraryofcambodia.org

ពួកយើងខំរកស៊ីបែកញើសហូរញើសសឹងក្លាយទៅជាឈាម អា-ចោរហានេយ្យាំងចាំតែមកស្កាត់ប្លន់អីចឹង ដូចងាយពេកហើយអ្ហី អ្ហា...ខ្ញុំត្រូវរបស់គេហើយ !

ទន្ទឹមនឹងកន្ទុយពាក្យស្រែកលាន់ទ្វីបលោក អ្នកជំនួញនោះ រលំដួលតូង ដោយសារមុខកាំបិតស្នៀតដែលចមចោរលបចោល ទៅត្រូវកណ្តាលទ្រូង ស្ទើររកមើលមិនទាន់ ។ ជនរងគ្រោះ ប្រកាច់ននៀលក្នុងថ្លុកលោហិត រួចដកចង្កាមាន់ដាច់ខ្យល់ស្លាប់ គួរឲ្យអាណោចអាធ័ម ។

លុះឃើញអំពើយង់ឃ្នងជាក់ស្តែងដូច្នេះ ពាណិជ្ជការទាំង អំបាលម៉ានចងកំហឹងពេញក្នុងដើមទ្រូង ម្នាក់ៗហាក់ចង់ស្ទុះចូល ទៅស៊ីសាច់ហុតឈាមអង្ស្យេមឆ្អឹងជនអន្ធពាលទាំងរស់។

ពេលដំណោលគ្នានោះ ត្រូគុនគ្រហឹមងឹលប្រៀបបាននឹង ខ្លាមានរបួស :

- ឯងថ្លើមខ្មៅណាស់ យើងត្រូវតែទទួលសងសឹកជូសគេ ជាដាច់ខាត !

www.elibraryofcambodia.org

- អី ! ចុះមាននរណាទៅថាអី ?

មួយប៉ប្រិចភ្នែកតែប៉ុណ្ណោះ មេក្រុមធានាដៃឆ្វេងក្តោបស្រោមដាវ ដៃស្តាំកាន់ដងហូតខ្វាក ! បញ្ចេញឲ្យឃើញផ្លែអាវុធសស្វាច ។ ឯចំណែកប្រមុខចោរក្រុមនាគសមុទ្រវិញក៏ឥតបង្អែបង្អង់ដែរ ជនទ្រើសឃ្នងដកសស្ត្រាវុធចាំរ៉ាប់រងជាស្រេច ។ គូប្រយុទ្ធទាំងពីរវេក្រសែចក្នុរកមើលចំណុចខ្សោយម្ខាង១ តែរៀងខ្លួន មិនយូរប៉ុន្មាន ទ្វេជនហក់លោតរកគ្នាយ៉ាងសាហាវ ។ ផ្លែដាវប្រគំប្រកួតបង្ហូតក្បាច់ដណ្តើមឈ្នះ កាប់រះលើក្រោមវក់វីពេញទីសំពៅ ។

នៅពេលបន្ទាន់គ្នានោះ សិស្សគណរបស់មេក្រុមធានាបានបើកឆាកតស៊ូនឹងពពួកជនពាលបន្តមកទៀត ដោយមានឈ្នួញទាំងអស់ និងទូតានុទូត ជាពិសេសជួយចាក់សម្លាប់កាប់សម្លេះចោរសមុទ្រ រហូតដល់បង្កើតបានជាឆាកប្រឡូកគ្នាលែងដឹងទិសតំបន់។ ចោរចិនខ្លះត្រូវរបួសហូរឈាមកក្លិកកក្លាក់ដូចឆ្កែកំបែកក្បាល ខ្លះភ្លាត់ចំណាប់ធ្លាក់ទឹកស្លាប់ រកតែហាមាត់ស្រែកលាពិភពលោកមិនទាន់ផង ។

www.elibraryofcambodia.org

រីឯមេក្រុមធានានិងចមចោរនាគសមុទ្រ ហាក់មានថ្វីដៃប្រហាក់ប្រហែលគ្នា នរណាក៏រកស្នៀតបំបែកពុំឃើញដែរ តែម្នាក់ៗនៅទ្រាំទ្រប្រយុទ្ធគ្មានរារែកចិត្តសោះឡើយ ។ មហាចោរចងចិញ្ចើមញញួញធ្មេញជម្រុះសម្ដីថា :

- ដៃគួខ្លាំងក្លាដូចកញ្ចាស់ឯង អញកម្របានជួបប្រទះណាស់ ប៉ុន្តែអញសុំបញ្ជាក់ប្រាប់ចុងក្រោយបង្អស់ថា ត្រូវគុនល្បីល្បាញយ៉ាងណាក៏ដោយ ឲ្យតែបានជល់នឹងមេក្រុមនាគសមុទ្រអញនេះ ច្បាស់ជាចៀសមិនផុតពីស្លាប់តាយហោងទេ !

- ឥឡូវកញ្ចាស់យើងចង់ដឹងដែរថា អាចោរចិត្តពាលណោដែលធ្វើមធំហ៊ានប្រមាថយើង ដូចរូបឯងជាដើម តើអាចនៅរស់រានមានជីវិតតទៅទៀតបានទេ ?

រហ័សវិស័យផ្ដេកបន្ទោរតម្រាមមេឃ ត្រួតុនវាត់ផ្លែដាវសំដៅតល់កបរបក្ស ក្នុងគោលបំណងទម្លាក់ក្បាលសត្រូវឲ្យដល់ក្ដីមរណមួយរំពេច ។ ឥតបានសម្រេចសោះ ព្រោះមហាចោរក៏រហ័សរហួនណាស់ដែរ ដៃឆ្វេងលើកស្រោមអាវុធឡើងកាត់រងឯដៃស្ដាំកាន់ដាវបុះសងមកវិញ :

www.elibraryofcambodia.org

- ស្លាប់ទៅអាកញ្ជាស់ !

បើតាមសន្ទុះស្មៀតនេះ មេក្រុមធានាប្រាកដជាចៀសមិនផុតពីគ្រោះថ្នាក់ទេ ។ តែនរណាទឹកស្មានដល់ថានៅក្នុងពេលប្រផុចញ៉ិចនោះ រាជទូតចេះតេចមកជួយយកអាសាទាន់ ដែលប្រមុខចោរចិនអត់ទ្រាំនឹងនិយាយដាក់ផ្លែផ្កាមិនបានឡើយ :

- ហាំ ! ហាំ ! គួរចាត់ទុកថាសំណាងរបស់កញ្ជាស់ឯងដែរ កុំតែមានគេជួយចូកចែវផង កញ្ជាស់ឯងប្រហែលទៅភ្លឺ ឯឋានបាតាលហើយ !

មន្ត្រីតំណាងក្រុងចិនវាយថយបន្តិច ដើម្បីឆ្លៀតយកឱកាសនិយាយឆ្លើយឆ្លង :

- ចំពោះអ្នកគុននិយមជើងឆើត គេពិតជាមិនញញើតជាមួយគូប្រយុទ្ធទេ !

- អញប្រមុខក្រុមនាគសមុទ្រក៏អឺចឹងដែរ !

- អ្នកបាទឯងដូចជាលើកកម្ពស់ខ្លួនឯងពេក...

រកតែរាជទូតស្រដីចប់ចុង ដើមមិនទាន់ មេក្រុមធានាគ្រេន្ទន់ខ្លួនគោរព ទន្ទឹមនឹងពាក្យពោលថា :

www.elibraryofcambodia.org

- សូមលោកមេត្តាទុកនាទីនេះឲ្យខ្ញុំចុះ ម្នាក់តតូជាមួយនាយក្រុមនាគសមុទ្រ បើទុកណាជាឈ្នះឬចាញ់ក៏គង់នៅល្អមើលដែរ !

- យល់ព្រម !

មាត់ឆ្លើយតបយ៉ាងខ្លីប៉ុណ្ណេះ រាជទូតដកឃ្លាថយទៅជួយវាយប្រហារអ្នកឯទៀតវិញ ។

កាលបើបានឱកាសល្អដូច្នេះហើយ គ្រូគុននិងមេចោរចិនពន្លះគ្នាសីងថា ចង់ស៊ីសាច់ជញ្ជក់ឈាមអង្គៀមស្បែកទាំងរស់ ។ មួយស្របក់ប៉ុណ្ណោះ ជនកំណាចដេញទីបុរសចំណាស់រហូតដល់ក្បាលសំពៅ :

- ប្រញាប់បញ្ចេញស្នៀតផ្តាច់ព្រ័ត្រភ្លាមមក៍ អញមិនបណ្តោយឲ្យអាកញ្ចាស់ឯងនៅរស់តទៅទៀតទេ !

- ប្រុងខ្លួន អ្ហា...

គ្រូគុនវាត់បានត្រឹមមួយដាវគត់ ក៏ត្រូវជនពាលអន្យតិរ្ថិយ៍កាប់ចំពាក់កណ្តាលខ្លួនទម្លាក់ទឹកបែកខ្ចាយ ឃើញតែឈាម

www.elibraryofcambodia.org

អណ្តែតត្រា ។ មហាចោរសមុទ្របែរខ្នងលើកដាវឡើង ស្រែកប្រកាសជោគជ័យឮក្តែងៗ ហាក់ដូចជាខំប្រឹងប្រែងតម្លើងសរសៃកខ្លាំងណាស់ :

- ក្រុមនាគសមុទ្រឈ្នះហើយ...អូយ...

ចមចោរចិនបន្លឺសម្រែកប៉ុន្មានម៉ាត់នេះ ស្ទើរផុតពីមាត់មិនទាន់ ក៏រលំដួលផ្កាប់មុខក្នុងថ្លុកលោហិតក្រហមច្រាលឆ្អៅ រួចប្រកាច់ប្រកិនរមៀលធ្លាក់ទឹកប្រូង ។ គួរបញ្ជាក់ថាសន្ទុះដាវរបស់គ្រូគុនជាមេក្រុមធានា ដែលបានបញ្ចេញស្ទៀតផ្តាច់ព្រ័ត្រមួយរំពេចនោះ ត្រូវចំចន្លោះក្បាច់ការពាររបស់មហាចោរ ធ្លាយពោះពុងចេញពោះវៀន ប៉ុន្តែជនពាលចិត្តរឹងខំយកដៃខ្ទប់ នៅស៊ុសងរហូតបានចំណោញតែស្លាប់ទាំងអស់គ្នា ។

រំពេចនោះ រាជទូត ឧបទូត និងត្រីទូត បន្តការដឹកនាំឆាកប្រយុទ្ធនេះយ៉ាងសកម្ម :

- ពួកយើងចូលកាប់សម្លាប់វាកុំឲ្យសល់ម្នាក់ !

- ខំប្រឹងប្រែងឡើង !

www.elibraryofcambodia.org

- ជ័យជម្នះប្រាកដជាធ្លាក់មកខាងយើងហើយ ក្រុមចោរនាគសមុទ្រត្រូវតែវិនាសផុតពូជ !

[illegible] ជាងច្រើន ម្នាក់ៗ [illegible] ដោយគ្មាន [illegible] :

- [illegible] :

[illegible] អន្ធពាលទាំងអំបាលម៉ាន ដែលមិនទាន់ចង់ស្លាប់មុនអាយុ ក៏ជំនាំគ្នាវាយដោះដៃហក់លោតផ្លូងទៅនាវានាគសមុទ្រវិញ ។

ឥតរវាណិតគ្មានអាសូរ ឲ្យចោរមិនរួចរស់ឈ្មោះជាមនុស្សតទៅទៀត រាជទូតលើកដៃឡើងដំណោលគ្នានឹងពាក្យពេញថា :

- ចាប់បាញ់ព្រួញភ្លើង សំដៅក្ដោងសំពៅ ពួកអានាគសមុទ្រភ្លាម !

ផុតពរលត់សំឡេងនេះសឹងមិនទាន់ ព្រួញភ្លើងរាប់សិបហោះហើរទៅឆាបឆេះក្ដោងធ្លាក់ដុំអគ្គី រាយពាសពេញក្នុងជល

www.elibraryofcambodia.org

យាន ។ មិនលើសពីមួយចម្អិនបាយ អគ្គិភ័យទំពាលេបសំពៅ ចោរសមុទ្រសន្ធោសន្ធៅ លាយឡំនឹងសម្រែកសប្បដិភ័យលាន់ព្រហឹង ។ សំពៅត្រាដែលធ្លាប់តែផ្ទុកជនពាលប្រាសចាកមនុស្សធម៌ អភោគទ្រព្យៗទុកមកពីអំពើលួចប្លន់ប្រចាំកអ្នកដទៃ លិចចុះត្រឹមៗទៅក្នុងបាតសាគរ សល់តែដងក្ដោងជាព្រាចុងឆ្ងើយ ។

អ្នកតំរោងស្រុកមិនបន្តដំណើរទៅស៊ើបសួរ មើលរឿងរ៉ាវទាំងនោះ ត្រាតែដឹងឮប្រាកដប្រជាដូចពាក្យហោរាទាយថ្វាយត្រូវមែន ។

ព្រះចៅក្រុងចិនទ្រង់ជ្រាបសព្វគ្រប់ហើយ ក៏បញ្ជាឲ្យមន្ត្រីនាំមាសប្រាក់ដាក់សំពៅប្រគេនតបព្រះតេជគុណ សម្ដេចព្រះសុគន្ធាមហាសង្ឃរាជាគណាធិបតីវិញជាច្រើន ។

www.elibraryofcambodia.org

# វគ្គទី៤

# អាម៉ៅខ្មែរ

នេះនឹងត្រឡប់ទៅនិយាយពីក្នុងរជ្ជកាលសម្តេចព្រះស្រីសុរិយោពណ៌ ដែលត្រូវជាព្រះអយ្យកោ (ជីតា) នៃព្រះរាជសម្ភារវិញ ។

នាកាលណោះ មានព្រះមហាថេរមួយអង្គព្រះនាមព្រះមហានាគគង់នៅវត្តកស្សប ។ ព្រះអង្គទ្រង់ប្រោសចិញ្ចឹមសុនខមួយឈ្មោះអាម៉ៅ ជាឆ្កែពូកែឲ្យដំណឹងក្រៃពេក ពោលគឺចេះដឹងបម្រើសម្តេចដូចសិស្សានុសិស្សនិងសទ្ធិវិហារិកដែរ ។

ពេលណាព្រះមហានាគថេរត្រូវការទិញអ្វីៗ ទ្រង់ធ្វើលិខិតច្រកក្នុងបំពង់ចងនឹងកអាម៉ៅ រួចមានពុទ្ធដីកាប្រាប់ថា :

- អាម៉ៅ ! ចូរឯងនាំយកសំបុត្រនេះទៅជូនសទ្ធិវិហារិកនៅកំពង់លួងផង !

www.elibraryofcambodia.org

សុនខសៃនចេះទម្លាក់អណ្តោត ប្រុងត្រចៀកត្រងត្រាប់ស្តាប់យល់ហើយ ក៏ស្ទុះបោលរឹងមួយរំពេច ។ នៅតាមផ្លូវមិនសូវមានឆ្កែណា ហ៊ានចេញមកយាយីទេ ព្រោះអាម៉ៅធ្លាប់បង្ក្រាបបាក់ស្បាតអស់ជាច្រើន ។ សោតបើឆ្កែស្រុក ភូមិឃើញឆ្កែខ្លួនក្តី ឬឆ្កែអ្នកដទៃក្តី ដែលចោមខាំអាម៉ៅ គេតែងតែនាំគ្នាដេញបំបែកចេញឆ្ងាយ ដើម្បីឲ្យសុនខរបស់សម្តេចព្រះមហានាគទៅមកបានស្រួល ។

នៅក្នុងស្រុកកំពង់លួងទាំងមូល ចាប់តាំងពីកូនក្មេងរហូតដល់មនុស្សចាស់ នរណាក៏ស្គាល់អាម៉ៅឆ្កែវត្តកស្សបដែរ ។ ពេលឃើញវាម្តង១ គេមិនភ្លេចនឹងចោលភ្នែកក្រឡេកមើល ដោយលួចសរសើរក្នុងពោះទេ ។

អាម៉ៅនាំសារ ដល់មាត់របងផ្ទះសិស្សគណសម្តេចហើយវាដកកព្រុសឲ្យដំណឹងភ្លាម ។ បើនៅតែពុំឃើញនរណាម្នាក់ចុះពីលើគេហដ្ឋានមកទៀត ឆ្កែចេះរត់ចូលទៅយកជើងមុខកាយកាំជណ្តើរឮក្រោក១ ។ សទ្ទិវិហារិកដែលសម្ងំលបចាំមើលសើចខឹក១ឡើង ៖

www.elibraryofcambodia.org

- នែ៎អាម៉ៅ ! ប៉ុណ្ណឹងចុះ... អញដឹងហើយ !

សិស្សគណព្រះមហានាគថេរ ចុះមកយកសំបុត្រពីក្នុងបំពង់នោះរួចត្រដាងអានភ្លាម ។ លុះដឹងសេចក្ដីក៏ងាកទៅ [illegible] អាម៉ៅ [illegible]

- ឯងត្រឡប់ទៅវិញចុះ !

ពេលព្រឹក ស្មេនខសែនទេះ ដែលលោកប្រវៀនចាំមួយកន្លែងព្រញាក់ព្រាត [illegible] ពេញក្រោមដំបូករំពេច ។

ឯតឡើវ [illegible] ផ្ទុះចេញពាក្យសំព្រួតលើកនាំគ្នាសែងក្ដុំ [illegible] ទៅប្រគេនសម្ដេចព្រះមហានាគជានិច្ច ។

ក្រោយមក អាម៉ៅកើតមានជំងឺខ្លាំងឡើងៗ រហូតដល់ដាច់បាយដាច់ទឹក ខ្លួនស្គាំងស្គមសល់តែស្បែកដណ្ដប់ឆ្អឹង ។ ទោះបីសម្ដេចព្រះមហានាគថេរ ខំប្រកបឱសថផ្ទាល់ព្រះហស្តព្រះអង្គចាប់តាំងពីវាឈឺតិចៗយ៉ាងណាក៏ដោយ ក៏ដូចជាមិនជល់សោះ ។ ទីបំផុត ឆ្កែចេះបានប្រគល់ជីវិតឲ្យទៅអាទិទេពវិញ តួរនឹកអាណិតស្រណោះ ។

www.elibraryofcambodia.org

ខណៈនោះ ព្រះមហានាគថេរប្រើសិស្សានុសិស្សថា :

- ចូរឯងយកអាម៉ៅទៅកាប់ឲ្យបានស្រួលបួលផង !

- ករុណា !

ទទួលពុទ្ធដីកាសម្តេចហើយ សិស្សពីររូបនាំគ្នាយក [illegible]

[illegible] ។

[illegible] ដែលអាម៉ៅខិតខំ [illegible]

[illegible] ។

[illegible] ព្រះរាជបុត្រ [illegible] នោះ បានឡើងសោយរាជ្យសម្បត្តិក្នុងក្រុងកាឆឹង(១) [illegible] ។

១- យោងតាមកំណត់ឯកសារប្រវត្តិសាស្ត្រខ្មែរ : តាមសាស្ត្រាសាមកុកថា ស្រុកកាឆឹងនេះមិនមែនជារាជធានីរបស់ស្តេចមានស្តេចព្រះ គឺជាស្រុករបស់ស្តេចត្រាញ់ ។ សាស្ត្រាដដែលនេះបានពំណោលថាកាល ឡៅពី គង់អ៊ូ ទាវហ៊ុយធ្វើសឹកនឹងចូអ៊្វ ហើយទទួលបរាជ័យ អ្នកទាំងបីរត់បែកខ្ញែកគ្នាម្នាក់ម្នាក់រៀងខ្លួន គឺគង់អ៊ូទៅចំណុះចូអ៊្វ ឯទាវហ៊ុយរត់ទៅនៅខែត្រមួយ គឺខែត្រកាឆឹងនេះឯង ។

www.elibraryofcambodia.org

ថ្ងៃមួយស្តេចចិនក្រុងកាឆឹងនេះ ទ្រង់ប្រឈួនព្រះកេស យ៉ាងខ្លាំង ព្រះអង្គយកព្រះហស្តឈ្លីធ្វើទីកព្រះភ័ក្ត្រស្ទុយបែ :

- អូ៎យ ! យើងឈឺក្បាលសឹងនឹងបែកហើយ សេវកា-មាត្យ... ប្រញាប់ទៅតាមពេទ្យហ្លួពូកែៗ មកភ្លាម !

- ព្រះករុណាថ្លៃវិសេស !

- ឯងទៅឲ្យលឿនឡើង !

ឥតហ៊ានបង្អង់ជើងទេ អ្នកបម្រើព្រះរាជារត់រកគ្រូច្រវ៉ាត់ច្រវ៉ែងគ្រប់ទិសទី ។ ប៉ុន្តែបានពេទ្យជំនាញការទាំងប៉ុន្មានចូលខ្លួនមកផ្សំឱសថថ្វាយដូចម្តេច ក៏ពុំជាសះស្បើយដែរ ។ អាការរោគហាក់ឋិតនៅដដែល ទាល់តម្រិះទាំងគ្រូហ្លួទាំងស្តេចព្រះចៅក្រុងកាឆឹងបែរមកប្រឹក្សានឹងហោរាចារ្យវិញម្តង :

- ត្រឹមរោគឈឺក្បាលប៉ុណ្ណេះ គ្រូពេទ្យពូកែៗទាំងអំបាលម៉ានបានចូលមកមើលយើងអស់ហើយ តែគ្មានឃើញបានស្រាកស្រាន្តសោះ តើមកពីហេតុអី ? ចូរហោរាឯងទស្សន៍ទាយឲ្យច្បាស់លាស់មើល៍ !

- សូមគោរពព្រះរាជឱង្ការ ក្រាបទូល !

www.elibraryofcambodia.org

ហោរាចារ្យដែលឆ្វេងទ្រក្តារឆ្នួន ដែលស្ពាំកាន់ដីសគូរវាស តាមក្បួនហោរាសាស្ត្រ ដោយខិតខំប្រើគំនិតគិតយ៉ាងល្អិតល្អន់។ អស់មួយស្របក់ ទើបយកសេចក្តីក្រាបថ្វាយបង្គំទូលព្រះចៅ :

- បើតាមជើងលេខ ដែលទូលព្រះបង្គំដេញមើលទៅឃើញថា...

ពោលមកដល់ត្រង់នេះ ហោរាបាក់នៅរារែកខ្លាចព្រះចេស្តា មិនហ៊ានក្រាបទូលការពិតតទៅទៀត ទាល់តែស្តេចគំហក :

- ម៉េចនិយាយបានប៉ុន្មានម៉ាត់ស្ងាត់វិញអ៊ីចឹង មិនចេះទាយទេអ្វី ឬមួយក៏ភ្លេចក្បួននៅឯផ្ទះ ?

- ទូលព្រះបង្គំសូមទ្រង់ព្រះមេត្តាប្រោស...

- យីអើ ! ឥឡូវហោរាឯងវាយលេខអត្ថះឃើញយ៉ាងម៉េច ឆ្លើយផ្ទូងៗភ្លាមមក៏ !

- បពិត្រព្រះករុណាដ៏ចម្រើន ! កាលពីជាតិមុនព្រះអង្គទ្រង់យកព្រះជាតិជាសុនខ មានលោកសង្ឃមួយអង្គ ក្នុងខេមរប្រទេសចិញ្ចឹមថែរក្សា ។ ដល់សុនខនោះឈឺស្លាប់ ព្រះសង្ឃ

www.elibraryofcambodia.org

ជាម្ចាស់បានចាត់ឲ្យសិស្ស យកទៅកប់មួយកន្លែងជិតគល់ឈើ។ នៅពេលឥឡូវនេះ ឬសឈើនោះដុះចាក់មកចំក្បាលសុនខហើយ ទើបព្រះអង្គប្រឈួនព្រះកេសដូច្នេះ ។ ទើបពេទ្យស្រុកចិនមើលថ្វាយមិនជាទេ លុះត្រាតែព្រះមហាថេរវិសេសមួយព្រះអង្គក្នុងក្រុងកម្ពុជាធិបតី ទើបអាចធ្វើឲ្យព្រះអង្គស្បើយពីព្រះរោគបានយ៉ាងសក្តិសិទ្ធ !

ក្សិណនោះ ស្ដេចផែនដីក្រុងកាឆឹងទឹកស្មានច្រឡំ :

- ហោរាទស្សន៍ទាយបែបនេះ ដើម្បីបង្អាប់បង្អោនព្រះកិត្តិយសរបស់អញកណ្ដាលជំនុំចំណោម...

ព្រះចៅទ្រង់ពិរោធខ្លាំងណាស់ រហូតដល់ភ្លាត់សូរសៀងទាំងក្ដៅក្រហាយ :

- យើះ ! អាហោរាកញ្ចាស់នេះថ្លើមធំមែន ហ៊ានហាមាត់ទាយបន្តុះបង្អាប់យើងផង... ក្រុមព្រះនគរបាល យកខ្លួនវាឃុំទុកមួយកន្លែងសិន ! ចាំយើងប្រើរាជទូតឲ្យទៅស៊ើបមើលដល់ក្រុងកម្ពុជា បើដឹងថាមិនប្រាកដដូច្នោះទេ យើងត្រូវដាក់ទោសវាប្រហារជីវិតបង់ !

www.elibraryofcambodia.org

- ទូលព្រះបង្គំទាំងអស់គ្នា សូមទទួលព្រះរាជបញ្ជាដ៏ខ្ពង់ខ្ពស់នៃព្រះករុណាជាអម្ចាស់ !

ពុំបង្អង់ ព្រះចៅចិនចាត់ឲ្យមន្ត្រីតែងព្រះរាជសារភ្លាម ។ ចប់សព្វគ្រប់ហើយ ទូតានុទូតក៏ត្រូវអញ្ជើញរាជសារនេះមកកាន់ខេមរប្រទេស ដោយធ្វើដំណើរតាមផ្លូវទឹកអស់រយៈពេលយ៉ាងយូរ ។

កាលដល់ក្រុងកម្ពុជាធិបតី អ្នកតំណាងស្រុកចិនបានចូលទៅជួបសម្ដេចចៅហ្វ៊ាទឡ្ហៈសមុហនាយ ឲ្យយកសេចក្ដីក្រាបទូលព្រះបាទសម្ដេចស្ដេចព្រះរាជឱង្ការ ព្រះស្រីធម្មរាជាធិរាជរាមាធិបតីនៅក្នុងព្រះបរមរាជវាំងកោះឃ្លោក ។

ព្រះរាជសម្ភារទទួលយកព្រះរាជសារ ដែលរាជទូតចិននាំមកថ្វាយព្រះអង្គហើយ ទ្រង់ប្រើអ្នកចេះប្រែភាសាថា :

- បកជាខ្មែរឲ្យក្បោះក្បាយទៅមើល៍ !

- ក្រាបទូល !

អ្នកបកប្រែលាតត្រដាងរាជសារឡើង ព្រមទាំងថ្វាយសេចក្ដីថា :

www.elibraryofcambodia.org

*ព្រះរាជសារសុន្ទរបវរ រាជមង្គលសាកល*

*ក្រុងកាឆីងរាជធានី*

*សូមចម្រើនផ្លូវព្រះរាជមេត្រី មកព្រះចៅក្រុងកម្ពុជាធិបតីបានទ្រង់ជ្រាប ។*

*ខ្ញុំនៅឯនាយ ពុំប្រកបដោយសុខភាពបរិបូណ៌ទេ ព្រោះកើតរោគប្រឈួនព្រះកេសជាទម្ងន់ ។ ហើយខ្ញុំដឹងថានៅក្នុងក្រុងកម្ពុជា មានព្រះមហាថេរមួយព្រះអង្គប្រសើរវិសេសណាស់ ហោរាទាយថា ទាល់តែព្រះមហាថេរអង្គនេះ ទើបអាចធ្វើឲ្យព្រះរោគរបស់ខ្ញុំបានជាសះស្បើយ ។*

*ដូច្នេះសូមព្រះមហាបពិត្រឋិតនៅឋានអាយ ជួយទំនុកបម្រុង សូមឲ្យព្រះមហាថេរអង្គនោះ មេត្តាដោះទុក្ខធុរៈតាមសេចក្តីប្រាថ្នានេះផង ។*

......................

លុះទ្រង់ព្រះសណ្តាប់ចប់ហើយ ព្រះរាជសម្ភារមានព្រះរាជបន្ទូលសួរសីហនាទថា :

- ដ្បិតឥឡូវនេះ ស្តេចចិនក្រុងកាឆីងបុរីមានព្រះរោគ

www.elibraryofcambodia.org

ប្រឈ្លួនព្រះកេសជាខ្លាំង ហើយព្រះអង្គចាត់រាជទូតឲ្យមកពឹងពាក់យើង គឺជាកិត្តិយសមួយធំណាស់ចំពោះក្រុងកម្ពុជាធិបតី ដូច្នេះយើងត្រូវតែជួយពេញដៃ-ជើង សូមលោកឧកញ៉ាព្រះតេ-ជោធិបតី និងព្រះឧកញ៉ាសិរីធម្មបញ្ញានាំរាជទូតចិននេះ ទៅថ្វាយបង្គំគាល់សម្ដេចព្រះសុគន្ធាមានបុណ្យផង !

- ព្រះរាជសម្ភារបារមីពិសេស !

ឧកញ៉ាព្រះតេជោធិបតី និងព្រះឧកញ៉ាសិរីធម្មបញ្ញា ថ្វាយបង្គំទទួលព្រះរាជឱង្ការ នាំនាម៉ឺនចិនតំណាងផែនដីការឹងបុរីទៅដល់វត្តអ្នកតាសឹងក្រុងឧត្តុង្គមានជ័យហើយ ក៏ក្រាបទូលសម្ដេចព្រះសុគន្ធាមហាសង្ឃរាជាគណាធិបតីជិម តាមហេតុគ្រប់ប្រការ ។

សម្ដេចព្រះសុគន្ធាមហាថេរទ្រង់ព្រះចិន្ដាថា :

- ពួកចិនអស់នេះ ពុំព្រមគោរពកោតក្រែងព្រះពុទ្ធសាសនាបានម្ដង ។

រំពេចនោះ ព្រះសុគន្ធាមានបុណ្យទ្រង់ចូលឈានសមាបត្តិ ដល់ពេលចាកចេញមកវិញ សម្ដេចទ្រង់មានថេរវាចាថា :

www.elibraryofcambodia.org

- កាលពីជាតិមុនឡើយ ព្រះចៅក្រុងកាឆឹងអង្គនេះជាសុនខរបស់លោកគ្រូព្រះមហានាគថេរ ។ ឆ្កែនោះឈ្មោះអាម៉ៅចេះគោរពប្រណិប័តន៍បម្រើលោកគ្រូវព្រះទ័យខ្លាំងណាស់ ។ លុះដល់វាឈឺស្លាប់ លោកគ្រូព្រះមហានាគថេរឲ្យសិស្សគណយកទៅកប់ប្របគុម្ពឫស្សីមួយ ដែលដុះខាងចុងភ្នំព្រះរាជទ្រព្យនៅទិសទក្សិណឆៀងអាគ្នេយ៍ ។ ដោយតេជកុសលទាំងអំបាលម៉ានដែលអាម៉ៅបានសាងក្នុងជាតិសុនខវត្តកស្សបនោះ ក៏យោនយកកំណើតកើតជាស្តេចចិនក្រុងកាឆឹងបុរីនេះឯង ។ ឥឡូវឫសឫស្សីដុះចាក់ចំក្បាលខ្មោចអាម៉ៅ ទើបស្តេចស្រុកចិនទ្រង់ព្រះឈឺព្រះកេសគ្មានស្បើយសោះ ។

អ្នកប្រែភាសាប្រាយប្រាប់រាជទូតចិន តាមព្រះពុទ្ធដីកាសម្តេចព្រះសុគន្ធាមហាសង្ឃរាជាសព្វគ្រប់ហើយ មន្ត្រីតំណាងក្រុងកាឆឹងក្រាបទូលថា :

- ត្រូវនឹងទំនាយហោរាមែន ! បើហេតុការណ៍ពិតជាកើតឡើងដូច្នេះ តើទូលព្រះបង្គំធ្វើយ៉ាងណា ដើម្បីឲ្យព្រះរោគព្រះករុណាជាសះស្បើយក្នុងពេលឆាប់ៗនេះ ?

www.elibraryofcambodia.org

ព្រះសុគន្ធាមហាថេរយល់សេចក្ដីរាជទូត ដោយសារមានអ្នកបកប្រែជាជំនួយ ព្រះអង្គទ្រង់ព្រះសិតាការ រួចបន្ទឹពុទ្ធដីកាថា :

- ព្រះអាការរោគរបស់ព្រះចៅក្រុងកាឆឹង មិនមែនពិបាករហូតដល់ទៅរកគ្រូហ្មប្រកបឱសថថ្វាយ នាំតែយ៉ាប់កម្លាំងឥតប្រយោជន៍នោះទេ ។ ជាការងាយសោះ គឺគ្រាន់តែអស់លោកទៅគាស់ជីកយកឫសឫស្សី ចេញពីរលហាដ៏ក្បាលអាម៉ៅវេលាណាស្ដេចក៏នឹងបានជាស្រាកស្រាន្តពុំខាន !

ពួកចិនដឹងឮដូច្នោះហើយ ប្រញាប់លុតជង្គង់ឱនកាយក្រាបថ្វាយបង្គំសម្ដេចព្រះសុគន្ធាផ្ដោម១ លាចេញទៅធ្វើតាមបង្គាប់ភ្លាម ។

ចិនព្រិនទាំងនោះជីកគាស់កកាយផ្នូរខ្មោចអាម៉ៅទៅ ក៏ឃើញឫសឫស្សីដុះជ្រែកចាក់ក្បាលផ្អែមែន ។ ម្នាក់១ដូចជានឹកអស្ចារ្យក្នុងចិត្តមិនតិចទេ ខ្លះលាន់មាត់ថាអឺចេះអឺចុះ :

- ហោរាចារ្យយើងទាយត្រូវគ្រាន់បើ !

- តែគួរឲ្យកោតសរសើរជាងហ្នឹងទៅទៀត ចំពោះព្រះ

www.elibraryofcambodia.org

ទិព្វញ្ញាណ នៃព្រះមហាថេរដ៏ប្រសើរវិសេស លើសលែងអស់មនុស្សផងទាំងពួងក្នុងលោក !

- បើនិយាយថា ព្រះមហាថេរអង្គនេះមានព្រះឱស្ឋទិព្វក៏សមរម្យម៉្យាងដែរ ព្រះអង្គចំជាអ្នកខ្លាំងពូកែរកគូប្រដូចគ្មាន។

និមិត្តតែដកប្ញសប្ញស្សី ចេញពីរលលាដ៏ក្បាលខ្មោចអាម៉ៅនៅខេមរប្រទេសឯណោះភ្លាម ព្រះចៅក្រុងកាឆឹងបុរីដែលមានព្រះរោគប្រឈួនព្រះកេសយ៉ាងធ្ងន់ ក៏បានជាស្រាកស្រាន្តបាត់ដូចគេបេះ ។

នៅក្នុងពេលដ៏ប្រពៃនោះ ស្តេចចិនទ្រង់សព្វព្រះរាជហឫទ័យត្រាស់បញ្ជាឲ្យកត់ថ្ងៃ ខែទុកជាចំណាំ ។

ឯរាជទូតទាំងប៉ុន្មាន នាំគ្នាខិតខំបំពេញកិច្ចការនានាចប់សព្វគ្រប់ហើយ អ្នកតំណាងក្រុងកាឆឹងចូលថ្វាយបង្គំលាសម្តេចព្រះសុគន្ធាមហាសង្ឃរាជាគណាធិបតីជិមនៅវត្តអ្នកតាសឹង វិលត្រឡប់ទៅកាន់ស្រុកចិនវិញ ។ ដោយយកកំណត់ថ្ងៃ ខែ ដែលបានគាស់ ដកយកប្ញសប្ញស្សីអស់ពីក្បាលខ្មោចអាម៉ៅ ចូលទូលស្តេច សូមទ្រង់ជ្រាបតាមដំណើរការណ៍ជាហូរហែ ។

www.elibraryofcambodia.org

ព្រះចៅចិនក្រុងកាឆឹង ផ្ទៀងផ្ទាត់ថ្ងៃខែមើលយល់ថា ត្រូវគ្នាគ្មានខុស គឺជាការពិតសក្តិសិទ្ធិដូច្នោះមែន ព្រះអង្គទ្រង់មានព្រះទ័យសោមនស្សពន់ពេកណាស់ :

- ចូរប្រញាប់ទៅដោះលែងលោកតាហោរាចារ្យចេញពីទីឃុំឃាំង ហើយនាំគាត់យកមកណេះភ្លាម !

នាម៉ឺនចិនប៉ុន្មាននាក់ ក្នុងសម្លៀកបំពាក់ឯកសណ្ឋានជាក្រុមព្រះនគរបាល ឱនកាយផ្គុំដៃគោរពព្រះរាជបញ្ជា :

- សូមទទួលព្រះរាជឱង្ការតម្កល់លើត្បូងក្រាបទូល !

មន្ត្រីទាំងនេះចេញទៅបាត់មួយសន្ទុះ ទើបលេចមុខចូលមកវិញ ដោយមានហោរារួមដំណើរផង ។

តាហោរាទ្រង់បុកពោះប៉ផ្អុក ព្រោះដឹងមិនដល់ព្រះទ័យស្តេច ដែលទ្រង់បង្គាប់ឲ្យគេទៅយកខ្លួនចូលមកក្នុងពេលនេះ ។ បុរសចំណាស់ធ្វើគារវកិច្ចយ៉ាងសមសួន ទ្រង់សុំសេចក្តីសន្តោសប្រោសប្រាណពីស្តេចផែនដី ដែលដាក់ទោសរូបគាត់ ដោយយកកំហែងទល់កំហល់ពុំព្រមទ្រង់ព្រះចិន្តាវែងឆ្ងាយសោះ :

- ទូលព្រះបង្គំជាខ្ញុំ សូមក្រាបក្រោមលម្អងធូលីព្រះបាទ...

www.elibraryofcambodia.org

ខណៈនោះ ព្រះចៅក្រុងកាឆឹងបុរីទ្រង់ព្រះសម្រួលជាប់ រដឹក ជាហេតុបណ្ដាលឲ្យហោរាចារ្យភិតភ័យតក្កមាមួយលើក ថែមទៀត ។ តែស្ដេចទ្រង់មានព្រះបន្ទូលប្រកបដោយទឹកព្រះភ័ក្ត្រស្រស់ស្រាយ :

- លោកតាហោរា ! ឥឡូវនេះ រាជទូតទាំងអស់ដែលយើងប្រើទៅកាន់ខេមរប្រទេស បានត្រឡប់មកវិញហើយ គេនាំដំណឹងពិតៗយកមកក្រាបបង្គំទូលយើង ដូចពាក្យលោកតាបានទស្សន៍ទាយពីខាងដើមមែន ។ អាស្រ័យហេតុដូច្នេះ យើងមានសេចក្ដីរីករាយនឹងជូនរង្វាន់ដ៏ជាទីគាប់ចិត្តដល់លោកតា ព្រមទាំងតែងតាំងក្នុងមុខតំណែង ជាហោរាចារ្យធំចម្បងក្នុងផែនដីកាឆឹង !

ហោរាចារ្យដើរត្រុនៗ ទៅទទួលយករង្វាន់ខាន់ខៅទាំងញ័រដៃទទ្រើក នឹងថាភ័យក៏ទេដែរ តែមកពីត្រេកអរនឹងជីវិតខ្លាំងពេក ព្រោះបានចាកផុតទុក្ខទោសរួចរស់ឈ្មោះជាមនុស្សតទៅទៀត :

- ជាព្រះករុណាទិគុណដ៏ឧត្ដម ដែលទូលព្រះបង្គំសុំតម្កល់ទុកក្នុងចិត្តដរាបដល់អវសានជីវិត !

www.elibraryofcambodia.org

- ប្រពៃហើយ...ចូរចម្រើនទាំងអស់គ្នាចុះ !

កាលបើស្តេចចិន ដែលពីជាតិមុនយកកំណើតជាអាម៉ៅ ឆ្កែខ្មែរ ជាសះស្បើយព្រះរោគាពាធហើយ នាម៉ឺនសព្វមុខមន្ត្រី គ្រប់តំណែងការ ក៏ហាក់បានសប្បាយរីករាយទៅតាមនោះដែរ ។

www.elibraryofcambodia.org

# វគ្គទី៥

## ប្រវត្តិផ្សេងៗ

ពេលនេះ ព្រះចៅចិនក្រុងការីឯងបុរីទ្រង់ជឿជាក់នូវរឿងរ៉ាវពីអតីតជាតិ ឥតបើមន្ទិលសង្ស័យសោះឡើយ ។ ព្រះអង្គឋិតនៅក្នុងតុណ្ហីភាពមួយសន្ទុះ ព្រោះស្តេចអាត់តែបណ្តែតអារម្មណ៍ឆ្លងដែនសីមាទៅឆ្ងាយ :

- ថ្វីដ្បិតជាតិនេះ អញមានភ័ព្វព្រេងសំណាងល្អ ចាប់កំណើតកើតក្នុងខត្តិយត្រកូលក្រុងចិន រហូតដល់បានឡើងគ្រប់គ្រងរាជសម្បត្តិនាដែនដីការីឯងក៏ដោយ ក៏អញមិនត្រូវបំភ្លេចជាតិជាសុនខនៅខេមរប្រទេសដែរ ។ ចំពោះដំណើរជីវិតមនុស្សម្នាក់ៗ ដែលវិលវល់កាត់វដ្តសង្សារអតីតកាល និងបច្ចុប្បន្នកាលប្រាកដជាស៊ីខ្សែទាក់ទងគ្នាមែន ។ បើពុំដូច្នោះទេអាត្មាអញកើតរោគឈឺក្បាលប៉ុណ្ណឹងហេតុអ្វីក៏គ្រូហ្មចំណាន១ ប្រកបឱសថ

www.elibraryofcambodia.org

មិនជល់សោះ ? ដល់ពេលជាស្រាកស្រាន្តវិញគឺងាយពេកស្ទើររកជឿពុំបាន ប៉ុន្តែរឿងនេះពិតណាស់ គ្រាន់តែរាជទូតគាស់កកាយឫសឫស្សីចេញពីរលលាដ៍ក្បាលខ្មោចអាម៉ៅភ្លាម ជំងឺតម្កាត់អញឯណោះបាត់ដូចគេបេះគ្រវែងចោល ដូច្នេះអញចាំបាច់នឹកគិតដល់ជាតិមុនផង ។

បន្ទាប់មក ស្ដេចបើកព្រះឱស្ឋបន្លឺព្រះសូរសៀងឡើង :

- យើងបានជាសះស្បើយស្ញែស្ញើយផុតទុក្ខ ក៏ដោយសារតែគុណូបការៈនៃព្រះបរមពិត្រក្រុងកម្ពុជាធិបតី និងសម្ដេចព្រះសុគន្ធាមហាសង្ឃរាជាគណាធិបតី គង់នៅវត្តអ្នកតាសឹងឧត្ដុង្គ-មានជ័យ ។ យើងត្រូវតែតបស្នងសងព្រះគុណលោកទាំងពីរវិញ..

ឆ្លៀតឱកាសដែលព្រះភូធរទ្រង់គង់ស្ងៀមបន្តិច មន្ត្រីខ្លះប្រញាប់ឱនកាយថ្វាយយោបល់ជាបន្តបន្ទាប់គ្នា :

- សូមព្រះតេជះតម្កល់លើត្បូង ! ព្រះរាជតម្រិះព្រះអង្គប្រសើរណាស់ សក្ដិសមជាព្រះមហាក្សត្រសោយរាជ្យមែនៗ !

- ព្រះអង្គមានព្រះទ័យប្រពៃគ្រប់ៗជាតិដូច្នេះ មហាមេឃនឹងជួយចម្រុងចម្រើនទ្រង់អស់កល្បកប្ប !

www.elibraryofcambodia.org

- ពិសេស ព្រះកិត្តិនាមព្រះអង្គនឹងល្បីរន្ទឺឮចេញឆ្ងាយទៅក្រៅប្រទេសផង !

ត្រូវនាម៉ឺនខ្លះប៉ិនប្រសប់ខាងវាយអែបស៊ីអុក បញ្ជោរលើកជើងកម្ពស់មេឃ ស្ដេចចិនទ្រង់ពេញព្រះទ័យយ៉ាងខ្លាំង :

- ហាំ ! ហាំ ! បើអ៊ីចឹងយើងសម្រេចថ្វាយរបស់មានតម្លៃតបព្រះគុណ និងបញ្ជូនពួកពលមួយរយនាក់ឲ្យទៅនៅថែរក្សាផ្នូរអាម៉ៅ ដោយចាត់ចែងធ្វើបុណ្យដុតក្រដាសមាសក្រដាសប្រាក់បូជារៀងរាល់រដូវ !

រំពេចនោះ នាម៉ឺនចាស់ទុំម្នាក់បន្ទន់ខ្លួនក្រាបបង្គំភ្លាម :

- ទូលព្រះបង្គំជាខ្ញុំ សូមទទួលយកព្រះរាជឱង្ការព្រះករុណាទៅចាត់ការឲ្យបានយ៉ាងឆាប់បំផុត !

- ល្អ...យើងទុកព្រះទ័យលើលោកហើយ ប្រសិនបើខ្វះខាតអ្វីៗរហ័សទូលយើងភ្លាម !

រំលងពីរបីថ្ងៃប៉ុណ្ណោះ ក្រោមព្រះរាជបញ្ជារបស់ព្រះរាជាក្រុងកាឆឹង មន្ត្រីចិនបានរៀបចំមាស ពេជ្រ ព្រៃ ទូនពលមួយរយនាក់ និងព្រះរាជសារពីរច្បាប់ បែងចែកផ្ទុកដាក់ក្នុង

www.elibraryofcambodia.org

ភត្រាពីរដាច់ដោយឡែកពីគ្នា គឺមួយសំពៅសម្រាប់ថ្វាយតប ព្រះគុណព្រះរាជសម្ភារព្រះចៅក្រុងកម្ពុជាធិបតី និងមួយសំពៅទៀត ចំពោះសម្តេចព្រះសុគន្ធាមហាសង្ឃរាជាគណាធិបតីជិមគង់នៅវត្តអ្នកតាសឹងឧត្តុង្គមានជ័យ ។

កាលបើចិនដឹកនាំវត្ថុមានតម្លៃនានា ចូលថ្វាយព្រះរាជសម្ភារហើយ ស្តេចទ្រង់ពេញព្រះទ័យពន់ពេក :

- យើងមានសេចក្តីសោមនស្សណាស់ ចំពោះកាយវិការដ៏ប្រសើរនៃព្រះចៅក្រុងការឹង តាងនាមអ្នកនគរក្រុងកម្ពុជាធិបតី និងក្នុងនាមយើងផ្ទាល់ យើងសូមសម្តែងនូវអំណរគុណជាពន្លឹក ។ ហេតុដូចបានថ្លែងមកហើយនេះ ចូររាជទូតនិងអស់លោកទាំងឡាយក្រាបទូលស្តេចឲ្យទ្រង់ជ្រាបសព្វគ្រប់ប្រការផង !

អ្នកតំណាងស្រុកចិនយល់ការតាមរយៈលោម[១] ម្នាក់រួចបង្គំទទួលព្រះរាជឱង្ការភ្លាម :

---

១- ពាក្យនេះប្រើតែក្នុងខេត្តបាត់ដំបងខ្លះ នៅសម័យពីដើម ដែលមានន័យថាអ្នកប្រែភាសា ។

www.elibraryofcambodia.org

- បរពិត្រល្អងធូលីព្រះបាទ ទូលព្រះបង្គំជាខ្ញុំទាំងអស់គ្នានឹងនាំព្រះបន្ទូលដ៏ខ្ពង់ខ្ពស់របស់ព្រះអង្គ ទៅក្រាបទូលព្រះករុណាមិនខាន !

នៅពេលដែលអ្នកបកភាសា ប្រែថ្វាយទ្រង់ជ្រាបហើយ ព្រះរាជសម្ភារជម្រុះព្រះសូរសៀងទាំងទឹកព្រះភ័ក្រ្តស្រស់បស់ :

- ឆ្លៀតឱកាសនេះ យើងសុំប្រសិទ្ធពរជ័យឲ្យលោករាល់គ្នាបំពេញកិច្ចការបានលទ្ធផលល្អ និងជួបប្រទះតែសេចក្តីសុខចម្រើនកុំបីឃ្លៀងឃ្លាតសោះឡើយ !

បន្ទាប់ពីនោះមក រាជទូតនិងមន្រ្តីចិនទាំងប៉ុន្មានប្រញាប់ដឹកជញ្ជូនភ័ស្តុភារយកទៅប្រគេនសម្តេចព្រះសុគន្ធាធិបតីភ្លាម ។

សម្តេចព្រះសុគន្ធាមហាសង្ឃរាជាគណាធិបតីជិម ទទួលយកបច្ច័យទាំងឡាយហើយ ព្រះអង្គបង្គាប់ថា :

- ចំណែកខាងពួកពលចិនមួយរយនាក់នោះ គួរតែនាំគ្នាទៅនៅកោះក្តាម ព្រោះមានសល់ដីទំនេរច្រើន បើនឹងចង់ប្រកបរបរធ្វើចម្ការច្បារដំណាំ ក៏ឃើញឥតទាស់អី !

www.elibraryofcambodia.org

យល់សេចក្ដីដោយសារអ្នកបកប្រែភាសាម្នាក់ ជាតំណាងចិនព្រិនទាំងមួយរយ រហ័សលើកដៃប្រណម្យចំពោះព្រះភ័ក្ត្រព្រះសុគន្ធាមហាថេរ :

- ករុណា...តាមតែព្រះអង្គទ្រង់មេត្តាប្រោសចុះ !

ចាប់តាំងពីពេលពលចិនមួយរយនាក់ទៅតាំងលំនៅឋានលើកោះក្ដាម ដោយគោរពតាមព្រះពុទ្ធដីកាសម្ដេចព្រះសុគន្ធាមហាសង្ឃរាជាមក អ្នកផងទាំងពួងបែរជាហៅទីនោះថា "កោះចិន " ដូច្នេះវិញ ។ សូម្បីដល់ពេលយូរយារក្រោយមកទៀត គេក៏នៅតែនាំគ្នាហៅកោះចិនដដែល ។

ព្រះសុគន្ធាធិបតី ចាប់អារម្មណ៍នឹងរឿងរវាម៉ៅ សុនខរបស់ព្រះគ្រូមហានាគថេរវត្តកស្សបណាស់ដែរ ព្រះអង្គឈ្វេងយល់ថា :

- គប្បីឲ្យគេកសាងចេតិយតូចមួយពីលើផ្នូរខ្មោចអាម៉ៅហើយមានតម្កល់ព្រះពុទ្ធរូបផង គ្រាន់នឹងចិនព្រិនណាមកថ្វាយបង្គំបានចម្រើនមគ្គផលទៅអនាគត ។

www.elibraryofcambodia.org

ពុំយូរប៉ុន្មាន សម្តេចចាត់ឲ្យជាងសាងចេតិយតាមសព្វព្រះរាជហឫទ័យដូច្នោះមែន ។

រីឯចិនទាំងប៉ុន្មាន ដែលតាំងទីលើកោះក្តាមហៅកោះចិន តែងតែធ្វើដំណើរឆ្លងទៅមក ដើម្បីធ្វើបុណ្យគោរពសពអាម៉ៅនៅកំពង់ខាងកើតរោងទូក ។ ពួកចិននោះមិនទាន់ចេះភាសាខ្មែរទេ គេនិយាយបានត្រឹមតែពាក្យ " ញ៉ៗ " ប៉ុណ្ណោះ ។ ហេតុដូច្នេះហើយទើបជាប់ឈ្មោះហៅថា " ភូមិពញាញ " ដរាបដល់សព្វថ្ងៃនេះ ។

រៀងរាល់ចូលឆ្នាំចិន ព្រះចៅក្រុងកាឆឹងតែងឲ្យមន្ត្រីជិះសំពៅមួយនាំយកទៀន ធូប ក្រដាសមាស ប្រាក់ និងគ្រឿងសក្ការៈបូជាផ្សេងៗទៀត មកអុជថ្វាយអាម៉ៅឆ្អែខ្មែរ ដើម្បីសេចក្តីសុខចម្រើនព្រះជន្មាយុយឺនយូរដល់ព្រះអង្គផង ។

ឱកាសនោះ សម្តេចព្រះសុគន្ធាមហាសង្ឃរាជាគណាធិបតីជិម ទ្រង់សព្វព្រះរាជហឫទ័យតាំងងារព្រះមហាថេរមួយអង្គនៅវត្តភ្នំជូនពេញជា " ព្រះចុឡាមុនី " សម្រាប់ជាន់ក្បាលសំពៅចិន ដែលរាជទូតជិះមកសែនព្រេនខ្មោចអាម៉ៅ ។

www.elibraryofcambodia.org

អាស្រ័យហេតុនេះបានជាចៅអធិការវត្តភ្នំ ជាប់ងារព្រះចុឡាមុនីរហូតមកដូច្នេះហោង ។

ឯទាំ

សរសេរចប់នៅស្រុកសិរីសោភ័ណ

ចុងខែកញ្ញា ១៩៧១

ស៊ូ ចំរើន

www.elibraryofcambodia.org

យើងខ្ញុំជាកូន ខ្ចៅ យុនសំរ៉ង ខ្ចៅ យ៉ាត់ណៃ ខ្ចៅសុខផល ខ្ចៅ វិសាល ខ្ចៅ វិមុន ខ្ចៅ ភារាដា ខ្ចៅ ចំរើន ខ្ចៅ ភារី

បានឧបត្ថម្ភការផ្សាយសៀវភៅនេះជាeBook

ដើម្បីឧទ្ទិសកុសលដល់វិញ្ញាណក្ខន្ធ ឧបាសក **ខ្ចៅ ពាញ** និង ឧបាសិកា **ឈរ យឿន**

ការផ្សាយសៀវភៅនេះជា eBook បានបង្កើតឡើងដោយ

**មូលនិធិខ្មែរសម្រាប់ការសិក្សា** និង **ករុណាខ្មែរ**

ដើម្បីបម្រើប្រយោជន៍ជាសាធារណៈ ដោយមិនគិតកម្រៃ

ស្កេន ជា eBook ដោយ **យី គិមយ៉ាត**

កញ្ញា ឆ្នាំ ២០១៥

បើលោក-លោកស្រីចង់បានសៀវភៅនេះ ឬអានបន្តទៅទៀត សូមទិញ ឬជាវពីអ្នកនិពន្ធ

ឬបណ្ណាគារដោយផ្ទាល់ដើម្បីគោរព "រក្សាសិទ្ធិ" របស់អ្នកនិពន្ធ។

យើងខ្ញុំ ពុំមានការព្រាស្រ័យទាក់ទង ដោយប្រភេទណាមួយជាមួយអ្នកនិពន្ធ ឬបណ្ណាគារទេ។

សូមអរគុណ

ខ្ចៅ យុនសំរ៉ង

ប្រធាន

មូលនិធិខ្មែរសម្រាប់ការសិក្សា

www.elibraryofcambodia.org